ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

# កម្រងវិញ្ញាសា និងអត្រាកំណែ

# ជីវវិទ្យា ថ្នាក់ទី១២

## ថ្នាក់វិទ្យាសាស្ត្រពិត

សម្រាប់ត្រៀមសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រ

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

រៀបរៀង និងចងក្រងដោយៈ

ក្រុមនិស្សិតស្ម័គ្រចិត្តក្រសួងអប់រំ យុវជន និងកីឡា

ឆ្នាំសិក្សា ២០១៩- ២០២០

សៀវភៅកម្រងវិញ្ញាសាជីវវិទ្យា

រៀបរាងដោយ

ក្រុមនិស្សិតសម្របសម្រួលក្លិបសិក្សាថ្នាក់ទី ១២

ស្ថិតនៅស្រុកកងមាស ខេត្តកំពង់ចាម

( វិទ្យាល័យហ៊ុនសែន កងតាណឹង , វិទ្យាល័យហ៊ុនសែន ខ្ចៅ និង វិទ្យាល័យហ៊ុនសែន ពាមជីកង )

បញ្ជីរាយនាម និស្សិតសម្របសម្រួល

១. ប៊ុន ដាលីន　　២. ណែម មុនីនាថ　　៣. ញ៉ឹក ជាវៃ

៤. ចាន់ ស្រីពៅជ　　៥.នោម សាម៉ុត　　៦. ទីន ភីហ្សា

៧. យឿន ស្រីតូច

ឆ្នាំសិក្សា ២០១៩ ~ ២០២០

# អារម្ភកថា

សៀវភៅ " **កម្រងវិញ្ញាសាជីវវិទ្យា** " នេះ គឺជាស្នាដៃដែលបានរៀបចំឡើងដោយក្រុមនិស្សិតស្ម័គ្រចិត្តចុះជួយសម្របសំរួលក្លិបសិក្សាដែលស្ថិតនៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម ។ នៅក្នុងកម្រងវិញ្ញាសានេះ ក្រុមរបស់យើងខ្ញុំបានធ្វើការ ដកស្រង់ និង ច្បិចយកចំនុចសំខាន់ៗទៅលើរូបមន្ត សំនួរ លំហាត់ផ្សេងៗ ដែលមាននៅក្នុងសៀវភៅឯកសារដែលបានចងក្រងដោយ ក្រសួងអប់រំ និង ឯកសារលំហាត់ត្រៀមប្រឡងផ្សេងៗទៀតដែលមានការរៀបចំឡើងដោយគ្រូឯកទេសទៅលើមុខវិជ្ជាជីវវិទ្យាផងដែរ ។

ជាការពិតណាស់ ការសិក្សាពីវិញ្ញាសានានាដែលធ្លាប់ចេញ និងការសិក្សាពីកម្រងវិញ្ញាសាបន្ថែមពិតជាមានសារៈសំខាន់ណាស់ ដើម្បីជាជំនួយស្មារតីដល់សិស្សានុសិស្សគ្រប់រូបក្នុងការត្រៀមប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាពេលខាងមុខ ឲទទួលបានជោគជ័យ ។ ដោយសារមើលឃើញពីសារៈសំខាន់នៃការសិក្សាឯកសារវិញ្ញាសាជីវវិទ្យា ដែលវាជាចំនួយបន្ថែមទៅដល់សិស្សានុសិស្ស ទើបក្រុមនិស្សិតស្ម័គ្រចិត្តមុខវិជ្ជាជីវវិទ្យាទាំងអស់គ្នាបានធ្វើការរៀបរៀងជាសៀវភៅមួយនេះឡើងមក ដើម្បីជាការងាយស្រួលដល់សិស្សានុសិស្សទាំងឡាយ ។ នៅក្នុងសៀវភៅមានទាំងរូបមន្ត វិញ្ញាសាដែលធ្លាប់បានចេញប្រលងកាលពីឆ្នាំ២០១៤ ដល់ ២០១៩ និងមានវិញ្ញាសាជំនួយបន្ថែមមួយចំនួនទៀត ដោយមានអមជាមួយនូវអត្រាកំណែផងដែរ ។

ជាចុងក្រោយ ក្រុមនិស្សិតស្ម័គ្រចិត្តនៃមុខវិជ្ជាជីវវិទ្យាទាំងអស់ដែលបានរួមគ្នាចងក្រងសៀវភៅកម្រងឯកសារជីវវិទ្យាមួយនេះឡើង ពិតជាមានចិត្តសោមនស្សរីករាយដែលបានចូលរួមចែករំលែកចំណេះដឹងទៅដល់សិស្សានុសិស្សដែលស្ថិតក្នុងស្រុកកងមាស ខេត្តកំពង់ចាម ។ ហើយកក្រុមរបស់យើងខ្ញុំក៏សូមខន្តីអភ័យទោសចំពោះ លោកគ្រូ អ្នកគ្រូ មិត្តអ្នកអាន និង សិស្សានុសិស្សទាំងអស់ នូវចំនុចអវិជ្ជមានដែលកើតមានដោយអចេតនានៅក្នុងសៀវភៅមួយនេះ ដោយក្តីអនុគ្រោះ ។

ថ្ងៃទី ១១កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

ត្រូវនឹង ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២០

# សេចក្ដីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំគឺជាក្រុមនិស្សិតស្មគ្រ័ចិត្ត ឯកទេសជីវវិទ្យា នៃក្រសួងអប់រំ យុវជន និងកីឡា ទាំងអស់គ្នា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅក្រៃលែង និង ពោរពេញដោយសេចក្ដីគោរព ចំពោះលោកអ្នកដែលមានគុណទាំងទ្វេរ ដែលមានផ្ដល់កំណើតឲយើងខ្ញុំទាំងអស់គ្នា ហើយបានចំណាយទាំងពេលវេលា និង ថវិកា ក្នុងការចញ្ចឹមបីបាច់ ទូន្មានប្រៀនប្រដៅកូនៗប្រកបដោយសេចក្ដីមេត្តាធម៌ ជាពិសេសលោកបានខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដោយបានបញ្ជូនកូនៗទៅរៀនសូត្រទទួលយកចំណេះដឹងរហូតទទួលបានជោគជ័យ និងបានក្លាយជាចំណែកធនធានមួយក្នុងសង្គម ព្រមទាំងអាចជួយបណ្ដុះបណ្ដាលធនធានថ្មីៗបន្ថែមទៀតផងដែរ ។

ជាកិច្ចបន្ទាប់ យើងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុង** រដ្ឋមន្ត្រី និងជាថ្នាក់ដឹកនាំនៃក្រសួងអប់រំទាំងអស់ ដែលបានយកចិត្តទុកដាក់បង្កើតឲមានក្លិបសិក្សានេះឡើង ដើម្បីឆ្លៀតឱកាសឲនិស្សិតទាំងអស់អាចបង្កើនចំណេះដឹង ពង្រឹងសមត្ថភាព អាចផ្ទេរបទពិសោធន៍ព្រមទាំងចែករំលែកចំណេះដឹងមួយចំនួនដើម្បីជួយពង្រឹងបន្ថែមទៅដល់ប្អូនៗសិស្សានុសិស្ស នៅក្នុងវិទ្យាល័យទាំង៣ ដែលស្ថិតនៅក្នុងស្រុកកងមាស ខេត្តកំពង់ចាម ឲទទួលបានលទ្ធផលល្អនៅក្នុងការប្រលងមធ្យមសិក្សាទុតិយភូមិនាពេលខាងមុខ ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** ដែលបានជួយផ្ដល់ជាអនុសាសន៍ ទ្រឹស្ដី យោបល់ ការណែនាំ និងដំណោះស្រាយផ្សេងៗដល់និស្សិតទាំងអស់ ដែលជាទុនក្នុងការធ្វើដំណើរការក្លិបសិក្សាឲទទួលបានជោគជ័យពីមួយឆ្នាំទៅមួយឆ្នាំ ។ មួយវិញទៀតយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ លោកស្រី **នៅ សុខម៉ាឌី** ដែលលោកស្រីបានជួយណែនាំ យកចិត្តទុកដាក់ ខិតខំទាំងកម្លាំងកាយចិត្ត ក្នុងការផ្ដល់មតិយោបល់ និងជួយកែលម្អនូវចំនុចខ្វះខាតផ្សេងៗ តម្រែតម្រង់ផ្លូវលើដំណើរការក្លិបសិក្សានេះតាំងពីចាប់ផ្ដើម រហូតទទួលបានជោគជ័យ ។ បន្ថែមពីនេះ ក្រុមរបស់យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យ គ្រូឧទ្ទេសទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយបង្ហាត់បង្រៀន និងផ្ដល់ចំណេះដឹងថែមទាំងដំបូន្មានល្អៗ មកកាន់ក្រុមនិស្សិតទាំងអស់។

ជាចុងក្រោយក្រុមនិស្សិតស្មគ្រ័ចិត្តទាំងអស់នៃមុនវិជ្ជាជីវវិទ្យា សូមគោរពជូនពរចំពោះ លោកឯកឧត្តមបណ្ឌិតសភាចារ្យ លោកឯកឧត្តមបណ្ឌិត លោកស្រី លោកគ្រូ អ្នកគ្រូ និង មិត្តរួមការងារទាំងអស់ ជួបប្រទះពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃទី ១១ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹង

ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២០

ក្រុមនិស្សិតស្មគ្រ័ចិត្តជីវវិទ្យា

# បញ្ជីសៀវភៅ


រូបមន្តដោះស្រាយលំហាត់ $ADN$ ........................................................................ 1

វិញ្ញាសាបាក់ឌុប ២០១៤ ........................................................................ 4

វិញ្ញាសាបាក់ឌុប ២០១៥ ........................................................................ 8

វិញ្ញាសាបាក់ឌុប ២០១៦ ........................................................................ 13

វិញ្ញាសាបាក់ឌុប ២០១៧ ........................................................................ 19

វិញ្ញាសាបាក់ឌុប ២០១៨ ........................................................................ 24

វិញ្ញាសាបាក់ឌុប ២០១៩ ........................................................................ 30


# វិញ្ញាសាត្រៀមប្រឡងបាក់ឌុប ២០២០


វិញ្ញាសាទី១ ........................................................................ 37

វិញ្ញាសាទី២ ........................................................................ 42

វិញ្ញាសាទី៣ ........................................................................ 48

វិញ្ញាសាទី៤ ........................................................................ 54

វិញ្ញាសាទី៥ ........................................................................ 58

វិញ្ញាសាទី៦ ........................................................................ 63

វិញ្ញាសាទី៧ ........................................................................ 67

# រូបមន្តដោះស្រាយលំហាត់ $ADN$

## ១ – រកចំនួននុយក្លេអូទីតសរុបរបស់ម៉ូលេគុល $ADN$ ឬសែន

តាមគោលការណ៍ពេញបាស $A-T, C-G$

$$A+T+C+G=M$$

តែ $A=T; C=G$

គេបាន៖ $2A+2C=M$

$-$ដើម្បីរក$M$ បើគេប្រាប់$A$ និងភាគរយ$\%A$

$$\Rightarrow M=\frac{A\times 100}{\%A}$$

$-$ដើម្បីរក$M$ បើគេប្រាប់$T$ និងភាគរយ $\%T$

$$\Rightarrow M=\frac{T\times 100}{\%T}$$

$-$ដើម្បីរក$M$ បើគេប្រាប់$C$ និងភាគរយ$\%C$

$$\Rightarrow M=\frac{C\times 100}{\%C}$$

$-$ដើម្បីរក$M$ បើគេប្រាប់$G$ និងភាគរយ$\%G$

$$\Rightarrow M=\frac{G\times 100}{\%G}$$

## ២ – រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ម៉ូលេគុល $ADN$ ឬសែន

$-$តាមគោលការណ៍បំពេញបាស$A-T; C-G \Rightarrow A=T; C=G$

$2A+AC=M$

$2(A+C)=M$

$$(A+C)=\frac{M}{2}$$

$$\Rightarrow A=T=\frac{M}{2}-C$$

$$\Rightarrow C=G=\frac{M}{2}-A$$

$-$បើគេស្គាល់$M$ និងសមាមាត្រភាគរយ$\%A$

$$\Rightarrow A=\frac{\%A\times M}{100}$$

$-$បើគេស្គាល់$M$ និងសមាមាត្រភាគរយ$\%T$

$\Rightarrow T = \frac{\%T \times M}{100}$

$-$បើគេសស្គាល់$M$ និងសមាមាត្រភាគរយ$\%C$

$\Rightarrow C = \frac{\%C \times M}{100}$

$-$បើគេស្គាល់$M$ និងសមាមាត្រភាគរយ$\%G$

$\Rightarrow G = \frac{\%G \times M}{100}$

### ៣ – រកប្រវែង$ADN$ ឬសែន

$-$ដោយ$ADN$ ជាច្រវ៉ាក់ពីរស្របគ្នា ហើយនុយក្លេអូទីតមួយមានប្រវែង$0.34nm$

$\Rightarrow \ell = \frac{M}{2} \times 0.34$

$\ell$; ជាប្រវែង$ADN$ ឬសែន គិតជា$(nm)$

$M$ : ជានុយក្លេអូទីតសរុបរបស់ $ADN$ ឬសែន

### ៤ – រកចំនួនជំហាននៃម៉ូលេគុល$ADN$ ឬសែន

$-$ដោយមួយជំហានមានប្រវែង $3.4nm$

គេបាន: ចំនួនជំហាន$= \frac{\ell}{3.4}$

$-$ដោយមួយជំហានមាន$10$ គូបាសស្មើនឹង $20$ នុយក្លេអូទីត

គេបាន: ចំនួនជំហាន$= \frac{M}{20}$

### ៥ – រកចំនួនសម្ព័ន្ធអ៊ីដ្រូសែន

$-$ដោយ$A$ ភ្ជាប់$T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន$2$ និង$C$ ភ្ជាប់$G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន$3$

គេបាន: ចំនួនសម្ព័ន្ធអ៊ីដ្រូសែន $L = 2A + 3C$

### ៦ – រកភាគរយនុយក្លេអូទីត$(\%)$

$-$ដោយ$ADN$ ឬសែនមាននុយក្លេអូទីតបួនប្រភេទ

$\%A + \%T + \%C + \%G = 100\%$

តែ$A = T; C = G$

$2\%A + 2\%C = 100\%$

$2(\%A + \%C) = 100\%$

$\%A + \%C = 50\%$

$\Rightarrow \%A = 50\% - \%C$

$\Rightarrow \%C = 50 - \%A$

$-$ បើយើងស្គាល់នុយក្លេអូទីតសរុប$M$ និងនុយក្លេអូទីតប្រភេទ$A$

$\Rightarrow \%A = \frac{A \times 100}{M}$

– បើយើងស្គាល់នុយក្លេអូទីតសរុប$M$ និងនុយក្លេអូទីតប្រភេទ$T$

$\Rightarrow \%T = \frac{T \times 100}{M}$

– បើយើងស្គាល់នុយក្លេអូទីតសរុប$M$ និងនុយក្លេអូទីតប្រភេទ$C$

$\Rightarrow \%C = \frac{C \times 100}{M}$

– បើយើងស្គាល់នុយក្លេអូទីតសរុប$M$ និងនុយក្លេអូទីតប្រភេទ$G$

$\Rightarrow \%G = \frac{G \times 100}{M}$

### ៧– រកចំនួននុយក្លេអូទីតសេរីសរុប

– ដោយ$ADN$ ឬសែន$M$ ស្វ័យជំឡើងទ្វេ$n$ ដង$\rightarrow$ $ADN$ ឬសែនកូន$M \times 2^n$

$\Rightarrow M^{'} = M(2^n - 1)$

– បើ$ADN$ ឬសែនស្វ័យជំឡើងទ្វេនោះគេបាន:

$\Rightarrow M^{'} = M$

### ៨– រកចំនួននុយក្លេអូទីតសេរីប្រភេទនីមួយៗ $(A^{'};T^{'};C^{'};G^{'})$

តាមគោលការណ៍បំពេញបាស

$A^{'} - T; T^{'} - A; C^{'} - G; G^{'} - C$

ចំនួននុយក្លេអូទីតសេរី$A^{'} = T^{'} = A(2^n - 1)$

នុយក្លេអូទីតសេរី $C^{'} = G^{'} = C(2^n - 1)$

### ៩. រូបមន្តនៅលើច្រវ៉ាក់ម្ខាងៗនៃ $ADN$ ឬសែន

$\underline{A_1\ T_1\ C_1\ G_1}$ ច្រវ៉ាក់ទី

$\underline{A_2\ T_2\ C_2\ G_2}$ ច្រវ៉ាក់ទី២

– នុយក្លេអូទីតសរុបច្រវ៉ាក់ម្ខាង

$m = \frac{M}{2}$

$m = A_1 + T_1 + C_1 + G_1$

– ដើម្បីរកភាគរយនុយក្លេអូទីតច្រវ៉ាក់ម្ខាងៗ

$\%A_1 + \%T_1 + \%C_1 + \%G_1 = 100\%$

**ខ្នាតក្នុងជីវវិទ្យា**

$1nm = 10A^o \rightarrow 1A^o = 10^{-1}nm$

$1nm = 10^{-3}\mu m \rightarrow 1\mu m = 10^3 nm$

$1nm = 10^{-6}mm \rightarrow 1mm = 10^6 nm$

$1nm = 10^{-7}cm \rightarrow 1cm = 10^7 nm$

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ១៣ តុលា ២០១៤** | **មណ្ឌលប្រឡង**................................ |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩0នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**.................................... |
| | **ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. តើក្រពេញញើសមាននាទីដូចម្តេច?

II. តើអង់ទីប្សូទិចជាអ្វី?

III. ដូចម្តេចដែលហៅថាក្រពេញទីរ៉ូអ៊ីត? វាមាននាទីដូចម្តេច?

IV. តើហេតុអ្វីបានជាគេថាគ្រាប់លម្អងមិនមែនជាកាម៉េតឈ្មោល? ចូរពន្យល់។

V. តើចលនាការស្វ័យតម្លើងទ្វេ$ADN$ មានសារៈសំខាន់ដូចម្តេចខ្លះ?

VI. ហេតុអ្វីចាំបាច់ត្រូវមាន $ARN_t$ ($ARN$ ដឹកនាំ) ក្នុងសំយោគប្រូតេអ៊ីន?

VII. រាល់ម៉ូលេគុល $ADN$ ក្នុងកោសិកាមនុស្សមាន $6\times 10^9$ នុយក្លេអូទីត។

ក. តើប្រវែងម៉ូលេគុលទាំងអស់មានប៉ុន្មានមីលីម៉ែត្រ?

ខ. ហេតុដូចម្តេចបានជាប្រវែងទាំងនេះអាចរួញ ហើយស្ថិតនៅក្នុងណ្វៃយ៉ូកោសិកាដែលមានអង្កត់ផ្ចិតតែ $2-3$ ភាគពាន់នៃមីលីម៉ែត្រ?

VIII. ច្រវ៉ាក់ទោលមួយនៃម៉ូលេគុល $ADN$ មាន $3\times 10^4$ នុយក្លេអូទីត។

១. កាលណាម៉ូលេគុល ADN នៃធ្វើស្វ័យតម្លើងទ្វេ២លើកតើវាត្រូវការនុយក្លេអូទីតសេរីចំនួនប៉ុន្មាន?

២. ក្នុងម៉ូលេគុល $ADN$ នុយក្លេអូទីតនៃប្រភេទស៊ីតូស៊ីនស្មើនិង 14% នៃ ចំនួននុយក្លេអូទីតទាំងអស់។ គណនាចំនួននុយក្លេអូទីតនៃប្រភេទនីមួយៗរបស់ម៉ូលេគុល$ADN$ ។

៣. ម៉ូលេគុល $ADN$ នេះអាចប្រើជាគម្រូពុម្ពតើវាត្រូវការម៉ូលេគុល $ARN_m$ ប៉ុន្មានបើម៉ូលេគុល$ARN_m$ នីមួយៗមានជាមធ្យម $10^4$ នុយក្លេអូទីត?

# អត្រាកំណែ

I. ក្រពេញញើសមាននាទីបញ្ចេញញើសដើម្បីតម្រូវសីតុណ្ហភាពក្នុងសារពាង្គកាយ ឬវាមាននាទីបញ្ចេញសារជាតុពុលឬកាកសំណល់មេតាប៉ូលីស។

II. អង់ទីប្យូទិចគឺជាសារជាតុសាំញ៉ាំដែលផលិតដោយមីក្រូសារពាង្គកាយសម្រាប់ព្យាបាលជម្ងឺដែលបង្កឡើងដោយបាក់តេរី ឬ អង់ទីប្យូទិចគឺជាថ្នាំងសម្លាប់មេរោគ ឬជាថ្នាំផ្សះសម្លាប់មេរោគ។

III. ក្រពេញប៉ារ៉ាទីរ៉ូអ៊ីតជាក្រពេញរាងពងក្រពើតូចៗចំនួន៤ ដែលកបង្កប់ក្នុងផ្នែកខាងក្រោយនៃក្រពេញទីរ៉ូអ៊ីត។ វាមាននាទីបញ្ចេញឬផលិតអរម៉ូនប៉ារ៉ាទីរ៉ូអ៊ីត(PTH)។

IV. បានជាគេថាគ្រាប់លម្អងមិនមែនជាកាម៉ែតឈ្មោលព្រោះដោយសារតែ៖
- គ្រាប់លម្អងជាកោសិកាមានណ្វៃយ៉ូអាប្លូអ៊ីតពីរ ពោលគឺណ្វៃយ៉ូបន្តពូជ និងណ្វៃយ៉ូបន្តលូតលាស់។
- ណ្វៃយ៉ូលូតលាស់ហាក់បីដូចជានាំដំណើរការលូតលាស់នៃបំពងលម្អង។
- ណ្វៃយ៉ូបន្តពូជចែកតាមមីតូស១ដង បង្កើតជាស្ពែម៉ាតូសូអ៊ីតពីរ គ្មានផ្លាសែល។

ដូច្នេះ សរុបមកយើងឃើញថាគ្រាប់លម្អងមិនមែនជាកាម៉ែតឈ្មោលទេ។

V. ចលនាស្វ័យតម្លើងទ្វេ ADN វាមានសារៈសំខាន់ដែលមានដូចជា៖
- រក្សាចំនួនក្រូម៉ូសូមឲ្យនៅដដែលពេលកោសិកាចែក។
- នៅចំណែកមេតូស កោសិកាមេនិងកោសិកាកូនមាន AND ដូចគ្នា។
- រ៉ាប់រងចំនួន និងរូបរាងក្រូម៉ូសូមឲ្យនៅដដែលក្រោយចំណែកកោសិកា។
- រ៉ាប់រង និងតំហែរក្សាពត៌មានសេនេទិចឲ្យនៅថេរដោយឆ្លងកាត់ជំនាន់។

VI. បានជាក្នុងការសំយោគប្រូតេអ៊ីនចាំបាច់ត្រូវមាន $ARN_t$($ARN$ ដឹកនាំ)ព្រោះតែ៖
- $ARN_t$វាមាននាទីដឹកនាំអាស៊ីតអាមីនេពីសីតូប្លាសចូលទៅក្នុងរីបូសូម និងតម្រូវអង់ទីកូដុងជាមួយកូដុងរបស់ $ARN_t$។
- ឬ$ARN_t$ មាននាទីភ្ជាប់(ដឹកនាំ) អាស៊ីតអាមីនេយថាប្រភេទមួយ ហើយវាទទួលស្គាល់កូដុងរបស់ $ARN_m$ ដោយសារអង់ទីកូដុង។

VII. រាល់ម៉ូលេគុល$ADN$ ក្នុងកោសិកាមនុស្សមាន $6\times10^9$ នុយក្លេអូទីត

ក. គណនាប្រវែងម៉ូលេគុលADN ជាមីលីម៉ែត្រ

តាមបម្រាប់ ម៉ូលេគុល$ADN$ មាន $M=6\times10^9$ នុយក្លអូទីត

ដោយចម្ងាយពីនុយក្លេអូទីតមួយទៅនុយក្លេអូទីតមួយទៀតមានប្រវែង $0.34nm$

គេបាន $\ell=\dfrac{M}{2}\times0.34$

នាំឲ្យ $\ell = \frac{6 \times 10^9}{2} \times 0.34 = 102 \times 10^7 nm$

ដោយ $1nm = 10^{-6}mm$

នាំឲ្យ $\ell = 102mm$

**ដូចនេះ** $\ell = 1020mm$

**ខ.** បានជាប្រវែងទាំងនេះអាចរួញហើយស្ថិតក្នុងណ្វៃយ៉ូកោសិកាដែលមានអង្កត់ផ្ចិតតែ 2 – 3 ភាគពាន់នៃមីលីម៉ែត្រព្រោះម៉ូលេគុល $ADN$ មានទម្រង់ជារង្វេលទ្វេ និងមានរូបរាងជាកីឡាម៉ង់ផ្ចារៗ( ស្ពៀរកម្មទ្វេ )។

VIII. ប្រវាក់ទោលមួយនៃម៉ូលេគុល $ADN$ មាន $3 \times 10 \times 4$ នុយក្លេអូទីត។

១. រកចំនួននុយក្លេអូទីតសេរី $M'$ ដែលត្រូវការ

តាមបម្រាប់

- ប្រវាក់ទោលADN មាន $3 \times 10^4$ នុយក្លេអូទីត
- $ADN$ ស្វ័យតម្លើងទ្វេ2 ដង
- នុយក្លេអូទីតស៊ីតូស៊ីន $C = 14\% M$
- $ARN_m$ នីមួយៗមានជាមធ្យម $10^4$ នុយក្លេអូទីត តែដោយ $ADN$ មានប្រវាក់នុយក្លេអូទីត2 ខ្សែ នាំឲ្យ $M_{ADN} = 3 \times 10^4 \times 2 = 6 \times 10^2$ នុយក្លអូទីត

បើ $ADN$ មេមួយស្វ័យតម្លើងទ្វេដំឡើងទ្វេះ

1 ដង បាន$ADN$ កូន $2^1$

2 ដង បាន$ADN$ កូន $2^2$

3 ដង បាន$ADN$ កូន$2^3$

...

$n$ ដង បាន $ADN$ កូន $2^n$

ដោយម៉ូលេគុល $ADN$ ស្វ័យតម្លើងទ្វេ2 ដង

យើងបានADN កូនគឺ $2^2 = 4$ ក្នុងនោះមាន $ADN$ មេ1 កើតថ្មី 4-1

គេបាន $M' = M_{ADN}(2^2 - 1)$

$= 6 \times 10^4 \times 3 = 18 \times 10^4$ នុយក្លេអូទីត

**ដូចនេះ** $M' = 18 \times 10^4$ នុយក្លេអូទីតសេរី

២. ក្នុងម៉ូលេគុល ADN នេះចំនួននុយក្លេអូទីតនៃប្រភេទស៊ីតូស៊ីនស្មើនិង 14% នៃចំនួននុយក្លេអូទីតទាំងអស់។

គណនាចំនួននុយក្លេអូទីតនៃប្រភេទនីមួយៗរបស់ម៉ូលេគុល ADN

តាមរូបមន្តនុយក្លេអូទីត $C = \frac{\%C \times M}{100}$

ដោយតាមបម្រាប់ $\%C = 14\%$

គេបាន $C = \frac{6\times 10^4 \times 14}{100} = 84\times 10^2$ នុយក្លេអូទីត

តាមគោលការណ៍បំពេញបាសនោះ

$A - T \ , C - G \Rightarrow A = T \ \ , C = G$

$$M = A + T + C + G$$
$$= 2A + 2G$$

$$\Rightarrow A = \frac{M}{2} - C$$
$$= 3\times 10^4 - 8.4\times 10^4$$
$$= 216\times 10^2$$

**ដូចនេះ** $A = T = 216\times 10^2$ នុយក្លេអូទីត

$C = G = 84\times 10^2$ នុយក្លេអូទីត

៣. រកចំនួនម៉ូលេគុល $ARN_m$ នេះ

ដោយ$ARN_m$ ទាំងអស់សំយោគទាំងអស់ចេញពីច្រវាក់ម្ខាងរបស់សែន

ដោយច្រវាក់ទោល $\frac{M}{2} = \frac{6\times 10^4}{2} = 3\times 10^4$ នុយក្លេអូទីត ហើយ $ARN_m$មួយមានមធ្យម $10^4$ នុយក្លេអូទីត

នាំឲ្យចំនួនម៉ូលេគុល$ARNm = \frac{3\times 10^4}{10^4} = 3$ ម៉ូលេគុល

**ដូចនេះ** ចំនួនម៉ូលេគុលទាំងអស់របស់ $ARN_m = 3$ ម៉ូលេគុល

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**<br>**សម័យប្រឡង ២៤ សីហា ២០១៥**<br>**វិញ្ញាសាៈ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)**<br>**រយៈពេលៈ ៩០នាទី ពិន្ទុ: ៧៥** | **សម័យប្រឡង**..................................<br>**មណ្ឌលប្រឡង**................................<br>**លេខបន្ទប់**..............**លេខតុ**................<br>**ឈ្មោះបេក្ខជ**.....................................<br>**ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. តើផ្នែកសំខាន់ៗនៃប្រព័ន្ធប្រសាទសត្វឆ្អឹងកងមានអ្វីខ្លះ?

II. ដូចម្តេចដែលហៅថាពន្លកជីភ្លាវិញ្ញាណ? ចូររៀបរាប់ទីតាំងនៃរសជាតិទាំង៤របស់អណ្តាត។

III. ១. ចូរសរសេររូបមន្តទូទៅរបស់អាស៊ីតអាមីនេ។

២. រ៉ាឌីកាល $R$ របស់អាស៊ីតអាមីនេនៃប្រភេទអាឡានី $-CH_3$

រ៉ាឌីកាល $R$ របស់អាស៊ីតអាមីនេនៃប្រភេទសេរីន $-CH_2OH$

ចូរសរសេររូបមន្តគីមីនៃអាស៊ីតអាមីនេទាំងពីរ

៣. ចូរសរសេររូបមន្តឌីប៉ិបទីតដែលកើតចេញពីអាស៊ីតអាមីនេទាំងពីរនេះ។

IV. តើផូស៊ីលជាអ្វី? ការកកើតផូស៊ីលមានប៉ុន្មានរបៀប? អ្វីខ្លះ?

V. ហេតុអ្វីបានជាគេចាត់ទុក ក្រពះនិងពោះវៀនតូចជាក្រពេញអង់ដូគ្រីន ?

VI. សែនមួយមានផលបូកនុយក្លេអូទីតប្រភេទ $A$ និង $T$ ស្មើនឹង 25% នៃនុយក្លេអូទីតទាំងអស់ ហើយមានចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុប 1287 ។

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយរបស់សែន?

ខ. រកចំនួនសម្ព័ន្ធអ៊ីដ្រូសែនរវាង $C$ និង $G$ , $A$ និង $T$ ។

VII. សែនមួយមាននុយក្លេអូទីតសរុប 14400 ។

ក. រកប្រវែងរបស់សែនគិតជាមីក្រូម៉ែត្រ?

ខ. គណនាចំនួនអាស៊ីតអាមីនេនៅក្នុងម៉ូលេគុលដែលសំយោគចេញពីសែននេះ?

គ. គណនាល្បឿនរបស់រីបូសូម បើដឹងថាបម្លាស់ពីដើមម៉ូលេគុល $ARNm$ រហូតដល់ចុងម៉ូលេគុលប្រើរយៈពេល 80 នាទី។

# អត្រាកំណែ

I. ផ្នែកសំខាន់ៗនៃប្រព័ន្ធប្រសាទសត្វឆ្អឹងកងមាន២ផ្នែកគឺ មជ្ឈមណ្ឌលប្រសាទ និង បរិមណ្ឌលប្រសាទ
- មជ្ឈមណ្ឌលប្រសាទមានខួរក្បាលនិងខួរឆ្អឹងខ្នង
- បរិមណ្ឌលប្រសាទមាន ផ្លូវប្រសាទ វិញ្ញាណនាំ និងផ្លូវប្រសាទចលករ

II. ពន្លកជីវ្ហាវិញ្ញាណគឺជាធ្នូលវិញ្ញាណគីមីដែលរួសនិងរសជាតិឬធ្នូលវិញ្ញាណរសជាតិ។ ទីតាំងនៃរសជាតិ
- រសជាតិផ្អែមស្ថិតនៅផ្នែកចុងអណ្ដាត
- រសជាតិប្រៃស្ថិតនៅផ្នែកចំហៀងសងខាង( ផ្នែកមុខ )
- រសជាតិជូរស្ថិតនៅចំហៀងសងខាង( ផ្នែកបន្ទាប់ )
- រសជាតិល្វីង ស្ថិតនៅគល់អណ្ដាត។

III. ១. រូបមន្តទូទៅអាស៊ីតអាមីនេ

$$NH_2 - \underset{\substack{| \\ R}}{CH} - COOH$$

២. អាស៊ីតអាមីនេអាឡានីន

$$NH_2 - \underset{\substack{| \\ CH_3}}{CH} - COOH$$

អាស៊ីតអាមីនេសេរីន

$$NH_2 - \underset{\substack{| \\ CH_2OH}}{CH} - COOH$$

៣.ឌីប៉ិបទិត

$$NH_2 - \underset{\substack{| \\ CH_3}}{CH} - CO - NH - \underset{\substack{| \\ CH_3}}{CH} - COOH$$

IV. ផូស៊ីលជាស្នាម ឬសំណល់ភាវៈរស់ដែលបានបន្សល់ទុកនៅសម័យយូរលង់ណាស់មកហើយ។

ដំណើរកកើតផូស៊ីលមានបីរបៀបៈ
- ដំណើរក្លាយជាថ្ម សំណល់ភាវៈរស់ខ្លះដែលកប់ជាប់ក្នុង កម្ទេចកំណាប្លែងជាថ្ម
- ពុម្ពក្រៅនិងពុម្ពក្នុង

ពុម្ពក្រៅពេលដែលសារពាង្គកាយកប់ក្នុងកម្ទេចកំណត្រូវក្លាយជាបន្តិចម្តងៗហើយបន្សល់ទុកទទេ។

ពុម្ពក្នុងទឹកហូរនាំកម្ទេចកំណមកចាក់បំពេញពុម្ពនោះបង្កើតបានជាពុម្ពក្នុងដែលប្លែងជាសិលាមានទ្រង់ទ្រាយដូចសារពាង្គកាយ

- ការបន្សល់ទុកសារពាង្គកាយនៅទាំងមូលកប់ក្នុងជ័រុក្ខជាតិឬទឹកកក។

V. ក្រពះនិងពោះវៀនតូចជាក្រពេញអង់ដូគ្រីនព្រោះវាជាក្រពេញដែលផលិតអរម៉ូនហើយបញ្ចេញទៅក្នុងចរន្តឈាមដោយផ្ទាល់

- ក្រពះផលិតអរម៉ូនកាស្ទ្រីន
- ពោះវៀនតូចផលិតអរម៉ូនសេក្រេទីន។

VI. ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន

បម្រាប់៖ ផលបូកនុយក្លេអូទីត $A$ និង $T$ ស្មើនិង 25% នៃនុយក្លេអូទីតទាំងអស់សម្ព័ន្ធអ៊ីដ្រូសែនសរុប 1287

⇨ $A = T\,;C = G$

⇨ $\%A + \%T = 2\%A = 25\%$

⇨ $\%A = 12.5\%$

ដោយ $\%A + \%C = 50\%$

⇨ $\%C = 50\% - \%A = 50 - 12.5 = 37.5\%$

⇨ $\%C = 37.5\%$

តាមការចងសម្ព័ន្ធអ៊ីដ្រូសែន

$A$ ភ្ជាប់ $T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 2

$C$ ភ្ជាប់ $G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 3

$L = 2A + 3C$

$$\Rightarrow 1287 = 2\left(\frac{12.5M}{100}\right) + 3\left(\frac{37.5M}{100}\right)$$

$$\Rightarrow \frac{25M}{100} + \frac{112.5M}{100} = 1287$$

$$\Rightarrow 137.5M = 128\,700$$

$$\Rightarrow M = \frac{128\,700}{137.5} = 936$$

គេបាន $A = \dfrac{12.5 \times 936}{100} = 117$ នុយក្លេអូទីត

គេបាន $C = \dfrac{37.5 \times 936}{100} = 351$ នុយក្លេអូទីត

**ដូចនេះ** នុយទីតប្រភេទនីមួយៗរបស់សែន $A = T = 117$ នុយក្លេអូទីត

$C = G = 351$ នុយក្លេអូទីត

ខ. រកចំនួនសម្ព័ន្ធរវាង $C$ និង $G$ ; $A$ និង $T$

សម្ព័ន្ធ$H$ រវាង $A$ និង $T$ $= 2A = 2\times117 = 234$

សម្ព័ន្ធ$H$ រវាង $C$ និង $G$ $= 3C = 3\times351 = 1053$

**ដូចនេះ** សម្ព័ន្ធអ៊ីដ្រូសែនរវាង $A$ និង $T$ $= 234$ សម្ព័ន្ធ$H$

$C$ និង $G$ $= 1053$ សម្ព័ន្ធ

VII. ក. រកប្រវែងសែនគិតជាមីក្រូម៉ែត្រ

បម្រាប់$M = 14400$ នុយក្លេអូទីត $t = 80mn$

ដោយប្រវែងនុយក្លេអូទីតមួយមានប្រវែង $0.34nm$

ហើយ ADN ច្រវ៉ាក់ទ្វេ(ប្រវែងនុយក្លេអូទីត$1$ ទៅនុយក្លេអូទីត$1$ ទៀត$= 0.34nm$

គេបាន $\ell = \dfrac{M}{2}\times 0.34$

$\ell = \dfrac{14400}{2}\times 0.34 = 2448nm$

ដោយ $1nm = 10^{-3}\mu m$

ដោយ $1nm = 10^{-3}\mu m$

**ដូចនេះ** ប្រវែង$\ell = 2448\times10^{-3}\mu m$

ខ. គណនាចំនួនអាស៊ីតអាមីនេ

នៅលើច្រវ៉ាក់ម្ខាងរបស់សែនមានត្រីជាតុ( $3$ នុយក្លេអូទីត)ជាក្រុមកំណត់អាស៊ីតអាមីនេ $1$ ។ ត្រីជាតុ$1$ ត្រូវនិងកូដុងផ្តើមកំណត់១មេត្យូនីន ហើយផ្តាច់ចេញត្រីជាតុ$1$ ទៀតត្រូវនិងកូដុងស្តុបមិនកំណត់អាស៊ីតអាមីនេទេ

⇨ ចំនួនអាស៊ីតអាមីនេ $\dfrac{M}{6} - 2$

$= \dfrac{14400}{6} - 2 = 2398aa$

**ដូចនេះ** ចំនួនអាស៊ីតអាមីនេ $= 2398$ a.a

គ. គណនាល្បឿនបម្លាស់ទីរបស់រីបូសូមលើម៉ូលេគុល$ARN_m$

បម្រាប់ $t = 80mn$

តាម $V = \frac{\ell_{ARNm}}{t}$

ដោយម៉ូលេគុល$ARNm$ សំយោគចេញពីច្រវ៉ាក់ម្ខាងនៃសែន

គេបាន $l_{ARN_m} = l_{\text{សែន}} = 2448nm$

$V = \frac{2440}{80} = 30.6nm/mn$

**ដូចនេះ** ល្បឿនរីបូសូម $V = 30.6nm/mn$ ឬ $V = 0.51nm/s$

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ២២ សីហា ២០១៦** | **មណ្ឌលប្រឡង**................................. |
| **វិញ្ញាសាៈ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេលៈ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**..................................... |
| | **ហត្ថលេខាបេក្ខជន**............................. |

## ប្រធាន

I. តើនៅក្នុងស្លឹកមានស្រទាប់អ្វីខ្លះ? តើស្រទាប់នីមួយៗមានតួនាទីដូចម្ដេចខ្លះ?

II. ហេតុអ្វីបានជាគេនិយាយថាអង់ស៊ីមជាប្រូតេអ៊ីនដែលមានសកម្មខ្លាំងក្លា?

III. ចូរប្រៀបធៀបប្រព័ន្ធប្រសាទសត្វឥតឆ្អឹងកង និងប្រព័ន្ធប្រសាទសត្វឆ្អឹងកង។

IV. តើវិស្វកម្មសេនេទិចជួយដល់រុក្ខជាតិអ្វីខ្លះ?

V. ក្រោយពេលស្វ័យតម្លើងទ្វេហើយ ហេតុអ្វីបានជាម៉ូលេគុល $ADN$ កូនដូចគ្នាបេះបិទទៅនិងម៉ូលេគុល$ADN$ មេ?

VI. ហេតុអ្វីបានជាអរម៉ូនភ្នោចតែកោសិកាគោលដៅ?

VII. ម៉ូលេគុល $ADN$ មួយមាននុយក្លេអូទីតប្រភេទ $C = 180000$ ដែលមានសមាមាត្រ 30% នៃនុយក្លេអូទីតទាំងអស់។

ក. រកភាគរយនុយក្លេអូទីតប្រភេទនីមួយៗ។

ខ. រកប្រវែងម៉ូលេគុល $ADN$ គិតជាមីក្រូម៉ែត្រ។

គ. រកចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុបរបស់ម៉ូលេគុល $ADN$ ។

VIII. សែនមួយមានប្រវែង680nm។ សែននេះកំណត់សំយោគ$ARNm$ មួយដែលមានទំនាក់ទំនងរវាងនុយក្លេអូទីត $2A - 3C = 3G - 2U$

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែននេះ។

ខ. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់$ARNm$ បើគេដឹងថាក្នុងម៉ូលេគុល $ARNm$ នេះមានផលដករវាង $A$ និង $U = 600$ ហើយផលដករវាង $C$ និង $G = 400$ ។

# អត្រាកំណែ

I. នៅក្នុងស្លឹករុក្ខជាតិមានស្រទាប់៖
   - អេពីឌែមលើ-ក្រោម
   - ស្រទាប់ប៉ាលីសាត
   - ស្រទាប់ស្ពោត។

   + ស្រទាប់នីមួយៗមាននាទី
   - ស្រទាប់អេពីឌែមលើ-ក្រោមមាននាទីការពារស្លឹករុក្ខជាតិនិងមានស្តូម៉ាតសម្រាប់បណ្តូរឧស្ម័ន និងទឹក។
   - ស្រទាប់ប៉ាលីសាតមានក្លរ៉ូប្លាសដែលផ្ទុកក្លរ៉ូភីលសម្រាប់ធ្វើរស្មីសំយោគ។
   - ស្រទាប់ស្ពោតមានសសៃស៊ីឡែម ផ្លូអែម និងរន្ធខ្យល់។

II. អង់ស៊ីមជាប្រូតេអ៊ីនមានសកម្មភាពខ្លាំងក្លា ព្រោះអង់ស៊ីមជាប្រូតេអ៊ីនមួយចំនួនតូចអាចបង្កើតប្រតិកម្មបានចំនួនធំ។

III. ប្រៀបធៀបប្រព័ន្ធប្រសាទសត្វឥតឆ្អឹងកងនិងសត្វឆ្អឹងកង
លក្ខណៈដូច៖
   - មានប្រព័ន្ធប្រសាទ
   - ទទួលពត៌មាន និងឆ្លើយតបទៅនិងពត៌មាន

លក្ខណៈខុសគ្នា៖
   - សត្វឥតឆ្អឹងកង
     - មានសេរីវាង្គវិញ្ញាណតិច
     - ខួរក្បាលមានទំហំតូចមានលក្ខណៈសមញ្ញ
     - គ្មានអឌ្ឍគោលខួរ និងខួរតូចទេ
   - សត្វឆ្អឹងកង
     - មានសេរីវាង្គវិញ្ញាណច្រើន
     - ខួរក្បាលមានទំហំធំនិងស្មុគស្មាញ
     - មានអឌ្ឍគោលខួរខ្លះធំ ខួរខ្លះតូច

IV. វិស្វកម្មសេនេទិចជួយដល់រុក្ខជាតិ៖
   - ធន់និងថ្នាំសម្លាប់សត្វល្អិត ធ្វើឲ្យរុក្ខជាតិធន់និងជម្ងឺ
   - ធន់និងអាកាសធាតុធ្វើឲ្យរុក្ខជាតិមានផ្លែផ្កាច្រើនធំៗ
   - បង្កើនគុណភាពដីដំណាំ

V. ក្រោយស្វ័យតម្លើងទ្វេម៉ូលេគុល$ADN$ កូនទាំង២ដូចគ្នាបេះបិទទៅនិងម៉ូលេគុល$ADN$ មេ ព្រោះពេលស្វ័យតម្លើងទ្វេច្រវ៉ាក់ទាំង២របស់$ADN$ មេធ្វើជាគម្រូ នុយក្លេអូទីតសេរីរត់ទៅបំពេញតាមគោលការណ៍បំពេញបាស $A-T, C-G$ ហេតុដូចនេះម៉ូលេគុល $ADN$ កូនទាំងពីរមានច្រវ៉ាក់ម្ខាងរបស់$ADN$ មេនិងច្រវ៉ាក់ម្ខាងទៀតជាច្រវ៉ាក់កើតថ្មីដែលដូចគ្នាបេះបិទទៅនិងម៉ូលេគុល$ADN$ មេ។

VI. អរម៉ូនភ្ញោចតែកោសិកាគោលដៅព្រោះកោសិកាគោលដៅមានធ្នួលនៅលើភ្នាស ដែលធ្នួលនៅលើភ្នាសកោសិកាគោលដៅមានទម្រង់ ត្រូវគ្នានិងអរម៉ូនដែលចង្កើតបានជាសារជាតុចម្រុះធ្នួលអរម៉ូន សារជាតុនេះហើយដែលធ្វើឲ្យកោសិកាឆ្លើយតបទៅនិងអំពើរបស់អរម៉ូន។

VII. ក. គណនាភាគរយនៃនុយក្លេអូទីតនីមួយៗ

បម្រាប់៖ $C = 180000$ នុយក្លេអូទីត

$\%C = 30\%$ នៃនុយក្លអូទីតសរុប

តាមគោលការណ៍បំពេញបាស

$$A-T\ , C-G \Rightarrow A=T\ , C=G$$

$$100\% = \%A + \%T + \%C + \%G$$

$$100\% = \%2A + \%2C$$

$$\Rightarrow \%A = 50\% - \%C$$

$$= 50\% - 30\% = 20\%$$

**ដូចនេះ** ភាគរយនៃនុយក្លេអូទីតនីមួយៗមាន

$$\%A = \%T = 20\%$$

$$\%C = \%G = 30\%$$

ខ. រកប្រវែងម៉ូលេគុល $ADN$ ជាមីក្រូម៉ែត

ដោយ $C = \dfrac{\%C \times M}{100}$

នាំឱ្យ $M = \dfrac{C \times 100}{\%C}$

$$M = \frac{180\,000 \times 100}{30} = 600\,000 \text{ នុយក្លេអូទីត}$$

ដោយ$ADN$ ជាច្រវ៉ាក់ទ្វេហើយពីនុយក្លេអូទីតមួយទៅនុយក្លអូទីតមា=នប្រវែង$0.34nm$

$$\ell = \frac{M}{2} \times 0.34$$

$$\ell = \frac{600\,000}{2} \times 0.34$$

$$= 102\,000nm$$

ដោយ $1nm = 10^{-3} nm$

**ដូចនេះ** $\ell = 102 \mu m$

គ. រកចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុប

ដោយ $A = \frac{20M}{100}$

$$A = \frac{20 \times 600\,000}{100} = 120\,000 \text{ នុយក្លេអូទីត}$$

ដោយ $A - T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 2 ជាន់

$C - G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 3 ជាន់

ចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុប

$L_H = 2A + 3C$

$= (2 \times 120\,000) + (3 \times 180\,000) = 780\,000$ សម្ព័ន្ធអ៊ីដ្រូសែន

**ដូចនេះ** $L_H = 780\,000$ សម្ព័ន្ធអ៊ីដ្រូសែន

VIII. ក. គណនាចំនួននុយក្លេអូទីតនីមួយៗរបស់សែន

បម្រាប់ ប្រវែងសែន $\ell = 680nm$

$2A - 3C = 3G - 2U$

$A - U = 600$ រីបូនុយក្លេអូទីត

$C - G = 400$ រីបូនុយក្លេអូទីត

ដោយសែនជាច្រវ៉ាក់ទ្វេហើយពីនុយក្លេអូទីតមួយទៅនុយក្លេអូទីតមួយទៀតមានប្រវែង

$0.34nm$

$\Rightarrow \ell = \frac{M}{2} \times 0.34$

$\Rightarrow M = \frac{2\ell}{0.34} = \frac{2 \times 680nm}{0.34nm} = 4000$ នុយក្លេអូទីត

ដោយ $2A - 3C = 3G - 2U$

$2A + 2U = 3C + 3G$

$2(A + U) = 3(C + G)$

តាមគោលការណ៍ចម្លងក្រម

Aសែន=Tសែន= $(A+U)_{ARNm}$

Cសែន=Gសែន= $(C+G)_{ARNm}$

$\Rightarrow 2(A+U)=3(C+G)$

$2A_{សែន}=3C_{សែន}$

តាមគោលការណ៍បំពេញបាស

$A-T\ \ ,C-G\Rightarrow A=T\ \ ,C=G$

$M=A+T+C+G$

$M=2A+2C$

$M=3C+2C=5C$

$\Rightarrow C=\frac{M}{5}=\frac{4000}{5}=800$ នុយក្លេអូទីត

គេបាន $A=\frac{M}{2}-C=\frac{4000}{2}-800=1200$ នុយក្លេអូទីត

**ដូចនេះ** នុយក្លេអូទីតប្រភេទនីមួយៗ $A=T=1200$ នុយក្លេអូទីត

$C=G=800$ នុយក្លេអូទីត

ខ. គណនាចំនួននុយក្លអូទីតនីមួយៗរបស់ $ARNm$

ដោយ $A-U=600$ នុយក្លេអូទីត $(1)$

$C-G=400$ នុយក្លេអូទីត $(2)$

ដោយ $A+U=1200$ នុយក្លេអូទីត $(3)$

$C+G=800$ នុយក្លេអូទីត $(4)$

តាម $(1)$ និង $(3)$

យើងបាន

$$\begin{cases}A-U=600 & (1)\\ A+U=1200 & (2)\end{cases}$$

$$2A=1800$$

$\Rightarrow A=\frac{1800}{2}=900$រីបូនុយក្លេអូទីត

$U=1200-A=1200-800=400$ រីបូនុយក្លេអូទីត

តាម (2) និង $(4)$ យើងបាន៖

$$\begin{cases} C - G = 400 & (2) \\ C + G = 800 & (4) \end{cases}$$

$$2C = 1200$$

$C = \frac{1200}{2} = 600$ រីបូនុយក្លេអូទីត

$G = 800 - C = 800 - 600 = 200$ រីបូនុយក្លេអុទីត

**ដូចនេះ** $ARNm$ មាន៖

| | |
|---|---|
| $A =$ 900 រីបូនុយក្លេអូទីត | $C =$ 600 រីបូនុយក្លេអូទីត |
| $U =$ 300 រីបូនុយក្លេអូទីត | $G =$ 200 រីបូនុយក្លេអូទីត |

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**................................... |
| **សម័យប្រឡង ២១ សីហា ២០១៧** | **មណ្ឌលប្រឡង**.................................. |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................. |
| **រយៈពេល៖ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**...................................... |
| | **ហត្ថលេខាបេក្ខជន**.............................. |

## ប្រធាន

I. តើគេអាចហៅឈ្មោះអង់ស៊ីមបានយ៉ាងត្រឹមត្រូវដោយផ្អែកលើកត្តាអ្វីខ្លះ?

II. តើពោតជារុក្ខជាតិម៉ូណូកូទីលេដូន ឬ ឌីកូទីលេដូន ?ហេតុអ្វី?

III. តើមានបាតុភូតអ្វីកើតឡើងនៅពេលដែលវីប៊ូសូមលោតដល់កូដុងស្តុប?

IV. តើកត្តាអ្វីខ្លះដែលបណ្តាលឲ្យកើតភាវៈរស់ប្រភេទថ្មី?ចូររៀបរាប់។

V. ប្រៀបធៀបក្រពេញអ៊ិចសូគ្រីន និងក្រពេញអង់ដូគ្រីន។

VI. ក. ដូចម្តេចដែលហៅថាអាំងក្លុចប្រសាទ?

ខ. ហេតុអ្វីបានជាពេលដែលមានរបួសដោយវត្ថុមុតស្រួចធ្វើឲ្យយើងមានការឈឺចាប់?

VII. ម៉ូលេគុល $ADN$ មួយមានសម្ព័ន្ធអ៊ីដ្រូសែនសរុប $16 \times 10^4$ ។ នុយក្លេអូទីតប្រភេទ $C$ ច្រើនជាងនុយក្លេអូទីតប្រភេទ $A$ ចំនួនពីរដង។

ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ $ADN$

ខ. ពេលម៉ូលេគុល ADN ស្វ័យតម្លើងទ្វេ៣ដង តើត្រូវការនុយក្លអូទីតសេរីនីមួយៗចំនួនប៉ុន្មាន?

VIII. ម៉ូលេគុល ARN នាំសារមួយមានសមាមាត្រជាភាគរយនៃនុយក្លេអូទីត

$U = 20\%$ $C = 20\%$ $A = 28\%$

ក. រកសមាមាត្រជាភាគរយនៃនុយក្លេអូទីតនីមួយៗនៃអង្គត់$ADN$ ដែលបានសំយោគម៉ូលេគុល $ARN$ នាំសាខាងលើ។

ខ. តើអង្គត់ $ADN$ នេះមានប្រវែងប៉ុន្មាន $(nm)$ បើ $U = 1800$

# អត្រាកំណែ

I. គេហៅឈ្មោះអង់ស៊ីមបានត្រឹមត្រូវដោយផ្អែកទៅលើកត្តា យថាប្រភេទនៃកាតាលីករដែលជំរុញល្បឿនប្រតិកម្មគីមីជីវៈ និងឈ្មោះស៊ុបស្ត្រាតបញ្ចប់ដោយពាក្យ(អាស)។

II. ពោតជារុក្ខជាតិម៉ូណូកូទីលេដូន ពីព្រោះ

- គ្រាប់របស់វាមានកូទីលេដុងមួយ
- ស្លឹករបស់វាមានទ្រនុងស្រប
- ដើមវាមានបាច់សសៃរាយប៉ាយ
- ផ្កាមាន3 ស្រទាប់ឬមេគុណនិង3
- ឫសជាឫសស្មៃ។

III. នៅពេលដែលរីបូសូមផ្លាស់ទីដល់កូដុងស្តុប សារធាតុចម្រុះទាំងអស់ទាំងអស់មាន $ARN_t$ រីបូសូមនិងច្រវ៉ាក់ប៉ូលីប៉ិបទីតដែលត្រូវបែងចេញពីគ្នាព្រោះកូដុងមិនត្រូវនិងអាស៊ីតអាមីនេណាមួយឡើយពេលនោះការសំយោគប្រូតេអ៊ីនត្រូវបានបញ្ចប់ ហើយមេត្យូនីនត្រូវបានផ្តាច់ចេញពីច្រវ៉ាក់ប៉ូលីប៉ិបទីតដែរ។

IV. កត្តាដែលធ្វើឲ្យកើតប្រភេទថ្មីមានពីរគឺៈ

- កត្តារបាំងភូមិសាស្ត្រ ពពួកផ្សេងៗត្រូវបែកចេញពីគ្នាហើយមិនអាចទំនាក់ទំនងជាមួយគ្នា។ ពពួកទាំងនោះមានលក្ខណៈខុសគ្នាកាន់តែច្រើនឡើងៗហើយមិនអាចបន្តពូជជាមួយគ្នាបានដូច្នេះក៏ក្លាយជាប្រភេទផ្សេងៗពីគ្នា។
- កត្តារបាំងជីវសាស្ត្រ ឯកត្តៈមានរូបរាងនិងទំហំប្រដាប់បន្តពូជខុសគ្នា។ ឯកត្តៈធ្វើការបន្តពូជនៅរដូវដល់ខែខុសគ្នា។ការទាក់ទាញរវាងសត្វញី និងសត្វឈ្មោលដើម្បីធ្វើការបន្តពូជមានរបៀបខុសគ្នា។

V. ប្រៀបធៀបក្រពេញអ៊ិចសូគ្រីន និងក្រពេញអង់ដូគ្រីន

\+ លក្ខណៈដូចគ្នាៈ

- ជាកោសិកាឬសរីរាង្គឬក្រពេញកើតពិកោសិកាអេពីតេល្យូម
- មាននាទី(ឯកទេសកម្ម)ក្នុងការបញ្ចេញសារធាតុចាំបាច់សម្រាប់សារពាង្គកាយ។

\+ លក្ខណៈខុសគ្នាៈ

ក្រពេញអង់ដូគ្រីន

- គ្មានបំពង់នាំ
- មាននាទីផលិតអរម៉ូន
- មានឥទ្ធិពលទៅលើកោសិកាគោលដៅ
- បញ្ចេញអរម៉ូនទៅក្នុងចរន្តឈាមដោយផ្ទាល់

ក្រពេញអ៊ិចសូគ្រីន

- មានបំពង់នាំ
- ផលិតរសរំលាយអាហារ សំណល់មេតាប៉ូលីស
- មានអំពើទៅលើសារធាតុណាមួយក្នុងលំហនៃសេរីរាង្គឬចេញក្រៅសារពាង្គកាយ
- បញ្ចេញរសតាមបំពងនាំដោយផ្ទាល់

VI. ក. អាំងភ្លុចប្រសាទជាពត៌មានដែលដឹកនាំតាមបណ្ដោយភីបប្រសាទ។

ខ.បានជាពេលដែលមានរបួសដោយវត្ថុមុតស្រួច ធ្វើឲ្យយើងមានការឈឺចាប់ពីព្រោះធ្នូលវិញ្ញាណឈឺចាប់លាតសន្ធឹងយ៉ាងច្រើនក្នុងស្រទាប់អេពីឌែមគឺរួសទៅនិងការឈឺចាប់។គ្រប់សសៃប្រសាទវិញ្ញាណនាំដែលទទួលរំញោចឈឺចាប់បានបញ្ជូនព័តមាននេះទៅកាន់សំបកខួរក្បាល( កំពកចំហៀងនៃខួរក្បាល )ដែលនៅទីនោះត្រូវបានវិភាគនិងបកស្រាយធ្វើឲ្យយើងឈឺចាប់។

VII. ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ $ADN$

តាមបម្រាប់ $L = 160000$ , $C = 2A$

ដោយ $A$ ភ្ជាប់$T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន $2$

$C$ ភ្ជាប់$G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន $3$

នាំឲ្យ $L = 2A + 3C$

$= 2A + 3(2A) = 160000$

$= 8A = 160000$

នាំឲ្យ $A = 20000$

$C = 2A = 40000$

តាមគោលការណ៍បំពេញបាស $A - T$ , $C - G$ នាំឲ្យ $A = T$, $C = G$

**ដូចនេះ** ចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ADN

$A = T = 20000$ នុយក្លេអូទីត

$C = G = 40000$ នុយក្លេអូទីត

ខ. គណនាចំនួននុយក្លអូទីតសេរីនីមួយៗ

$ADN$ មេ1 ស្វ័យតម្លើងទ្វេ 1ដងទទួលបាន $ADN$ កូន $2^1$

2ដងទទួលបាន ADNកូន $2^2$

3 ដងទទួលបាន ADNកូន $2^3$

……………………………………………………

$n$ ដងទទួលបាន $ADN$ កូន $2^n$

ដោយ$ADN$ មេមួយស្វ័យតម្លើងទ្វេ 3 ដងទទួលបាន $ADN$ កូន $2^3$ ក្នុងនោះមាន $ADN$ មេ1 និង $ADN$ កូនថ្មី$2^3-1$

$A'=T'=A\left(2^3-1\right)=20\,000\left(2^3-1\right)=140\,000$ នុយក្លេអុទីត

$C=G'=C\left(2^3-1\right)=40\,000\times 7=280\,000$ នុយក្លេអូទីត

**ដូចនេះ** ចំនួននុយក្លេអូទីតសេរីប្រភេទនីមួយៗរបស់$ADN$ គឺ

$A'=T'=140\,000$ នុយក្លេអូទីតសេរី

$C'=G'=280\,000$ នុយក្លេអូទីតសេរី

VIII. ក. រកសមាមាត្រជាភាគរយនៃនុយក្លេអូទីតនីមួយៗនៃអង្កត់ $ADN$

តាមបម្រាប់ $U=20\%$ , $C=20\%$ , $A=28\%$

ដោយ $ARNm$ មានវីបូនុយក្លេអូទីត៤ប្រភេទ $A,U,C,G$ ហើយវាជាច្រវ៉ាក់ទោល

$A+U+C+G=100\%$

$G=100\%-20\%-20\%-28\%=32\%$

តាមគោលការណ៍ចម្លងក្រម និងបំពេញបាស

%A$_{សែន}$ = %T$_{សែន}$ $=\dfrac{(\%A+\%U)_{ARnm}}{2}=\dfrac{20\%+28\%}{2}=24\%$

%C$_{សែន}$ = %G$_{សែន}$ $=\dfrac{(\%C+\%G)_{ARNm}}{2}=\dfrac{20\%+32\%}{2}=26\%$

**ដូចនេះ** ភាគរយនៃនុយក្លេអូទីតប្រភេទនីមួយៗរបស់អង្កត់ $ADN$

$\%A=\%T=24\%$

$\%C=\%G=26\%$

ខ. គណនាប្រវែងអង្កត់ADN នេះគិតជា ណាណូម៉ែត្រ

តាមបម្រាប់ $U=1800$

$\%U = \frac{U}{m} \times 100$

នាំឱ្យ $m = \frac{A \times 100}{\%A} = \frac{1800 \times 100}{20} = 9000$

ដោយ $ARNm$ ចម្លងចេញពីច្រវ៉ាក់ម្ខាងរបស់សែន

នាំឲ្យ $M = 2m = 9000 \times 2 = 18000$

ដោយសែនមានច្រវ៉ាក់ទ្វេ ហើយនុយក្លេអូទីតមួយមានប្រវែង $0.34nm$

នាំឲ្យ $\ell = \frac{M}{2} \times 0.34 = 9000 \times 0.34 = 3060nm$

**ដូចនេះ** ប្រវែងអង្កត់ $ADN$ គឺ $\ell = 3060nm$

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ២០ សីហា ២០១៨** | **មណ្ឌលប្រឡង**................................. |
| **វិញ្ញាសារ: ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**..................................... |
| | **ហត្ថលេខាបេក្ខជន**............................. |

## ប្រធាន

I. ដូចម្តេចដែលហៅថាអាំងភ្លុចប្រសាទ? តើអាំងភ្លុចប្រសាទឆ្លងកាត់ស៊ីណាប់យ៉ាងដូចម្តេច?

II. តើរលកសូរមានឥទ្ធិពលទៅលើផ្នែកផ្សេងៗនៃត្រចៀកយ៉ាងដូចម្តេច?

III. តើវិស្វកម្មសេនេទិចផ្តល់ផលល្អនិងផលអាក្រក់អ្វីខ្លះដល់មនុស្ស?

IV. ចូររកលក្ខណៈខុសគ្នារវាង៖

ក. រុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូន ។

ខ. ការបង្កាត់ជិត និងការបង្កាត់ឆ្ងាយ។

V. ក. តើអាំងស៊ុយលីនជាអ្វី? បើកង្វះអរម៉ូនអាំងស៊ុយលីនបណ្តាលឲ្យមានផលវិបាកអ្វីខ្លះ?

ខ. ចូរបកស្រាយពីរបៀបផលិតអរម៉ូនអាំងស៊ុយលីនដោយវិស្វកម្មសេនេទិច?

VI. ក. ចូររៀបរាប់ពីតួនាទីរបស់អង់ស៊ីម $ARN$ ប៉ូលីមេរ៉ាស។

ខ. ម៉ូលេគុល $ARN_m$ មួយមានទំនាក់ទំនងរវាបួនុយក្លេអូទីត $A = 4U$, $\frac{G}{C} = \frac{1}{2}$, $\frac{U}{G} = \frac{1}{5}$ គណនាភាគរយនុយក្លេអូទីតប្រភេទនីមួយៗរបស់អង្កត់ $ADN$ ដែលកំណត់សំយោគ $ARNm$ នេះ។

VII. ម៉ូលេគុល $ADN$ មួយមាននុយក្លេអូទីតប្រភេទ $C = 35\%$ នៃនុយក្លេអូទីតសរុប ហើយនុយក្លអូទីតប្រភេទ Cលើសនុយក្លេអូទីតប្រភេទ $A$ ចំនួន $4400$ ។

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់

ខ. តើម៉ូលេគុល$ADN$ នេះមានប៉ុន្មានជំហាន?

គ. បើម៉ូលេគុល $ADN$ នេះស្វ័យតម្លើងទ្វេ $4$ ដង តើវាត្រូវការនុយក្លអូទីតសេរីចំនួនប៉ុន្មាន?

# អត្រាកំណែ

I. អាំងភ្លុចប្រសាទជាពត៌មានដែលណឺរ៉ូនដឹកនាំ។ ឬអាំងភ្លុចប្រសាទជាពត៌មានដែលដឹកនាំតាមបណ្តោយណឺរ៉ូននៅចុងអាក់សូនមានថង់តូចៗជាច្រើនដែលដឹកនាំតាមបណ្តោយណឺរ៉ូននៅចុងអាក់សូនមានថង់តូចៗជាច្រើនដែលផ្ទុកសារធាតុគីមី (ណឺរ៉ូនបញ្ជូនសារ)។ពេលអាំងភ្លុចប្រសាទទៅដល់ចុងអាក់សូនថង់ទាំងនោះក៏ផ្ទុះបែកហើយបញ្ចេញណឺរ៉ូនបញ្ជូនសារសាយឆ្លងកាត់ស៊ីណាប់។បន្ទាប់មកណឺរ៉ូនបញ្ជូនសារនេះបង្កើតបានអាំងភ្លុចប្រសាទនៅក្នុងដង់ឌ្រីតរបស់ណឺរ៉ូនបន្ទាប់ រួចវាធ្វើដំណើរតាមតួកោសិកា និងចុះក្រោមតាមអាក់សូនរហូតដល់ចុងអាក់សូន។ ថង់តូចៗក៏ផ្ទុះបែកបញ្ចេញសារធាតុគីមី (ណឺរ៉ូនបញ្ជូនសារ)ទៅកាន់ស៊ីណាប់ សារធាតុគីមីនេះត្រូវបានភ្ជាប់បង្កើតបានជាអាំងភ្លុចប្រសាទថ្មីៗនៅក្នុងដង់ឌ្រីតហើយបញ្ជូនទៅក្នុងកោសិកាចុះតាមអាក់សូន។

II. រលកសូរមានឥទ្ធិពលទៅលើផ្នែកផ្សេងៗរបស់ត្រចៀក៖

- ត្រចៀកក្រៅ: ស្លឹកត្រចៀកប្រមូលផ្តុំរលកសូរហើយ រន្ធត្រចៀក(បំពង់សោតវិញ្ញាណ) ដឹកនាំរលកសូរទៅកាន់ត្រចៀកកណ្តាលដោយឆ្លងកាត់ក្រដាសត្រចៀក។ ក្រដាសត្រចៀកញ័រ ហើយលំញ័រត្រូវបានឆ្លងកាត់ត្រចៀកតាមឆ្អឹងតូចៗបី។ ឆ្អឹងទាំងបី ញ័របណ្តាលឲ្យភ្នាសបង្អួចរាងពងក្រពើញ័រ។ លំញ័រនៃភ្នាសនេះធ្វើឲ្យជាតុរាវក្នុងបំពងរាងគូទខ្យងញ័រ ដែលបណ្តាលឲ្យរោមល្អិតៗនៃកោសិកាផ្នួលក្នុងបំពងញ័រនោះ។ ក្រោយមកកោសិកាផ្នួលប្តូរលំញ័រទៅជាអាំងភ្លុចប្រសាទ។

III. វិស្វកម្មសេនេទិចផ្តល់ផលល្អនិងផលអាក្រក់ដលមនុស្ស៖

+ ផលល្អដល់មនុស្ស

  - ក្នុងវិស័យសុខាភិបាលៈ ផលិតអាំងស៊ុយលីន អាំងទែឡឺគីន អង់ទីប្យូទិច អង់ទីគ័រ វ៉ាក់សាំង។
  - ក្នុងវិស័យកសិកម្មៈ ធ្វើឲ្យរុក្ខជាតិមានផ្កាផ្លែ ធន់និងជម្ងឺ ធន់និងអាកាសធាតុ ធន់និងថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងជួយបង្កើនគុណភាពដីដំណាំ។
  - ក្នុងវិស័យឧស្សាហកម្មៈ ស្បៀងផលិតអាហារ មានអរម៉ូន ទឹកដោះគោជូរ ប្រូម៉ាសស្រាបៀរ នំប៉័ង

+ ផលអាក្រក់ដល់មនុស្ស

  - គ្រោះថ្នាក់ប៉ះពាល់ដល់បរិស្ថាន រុក្ខជាតិ$(GM)$ ធ្វើឲ្យបាត់បងជិវិត ជីវៈចម្រុះ សត្វល្អិតធន់និងរុក្ខជាតិ ($GM$ ) មានសកម្មភាពពុលដូចជារុក្ខជាតិ($GM$ )ធ្វើឲ្យរុក្ខជាតិអារ មិនអាចផលិតគ្រាប់លម្អងសម្រាប់បន្តពូជ។

- គ្រោះថ្នាក់ប៉ះពាល់ដល់សីលធម៌និងសង្គមៈ ធ្វើឲ្យសែនមុយតាស្យុងដែលមានឥទ្ធិពលអាក្រក់ដល់សណ្ដានក្រោយ ប៉ះពាល់ដល់សាសនា បែងចែកវណ្ណៈ(មានតែអ្នកមានទេទើបអាចធ្វើវិស្វកម្មសេនេទិចនេះបាន)។
- គ្រោះថ្នាក់ប៉ះពាល់ដល់សេដ្ឋកិច្ចៈ ក្រុមហ៊ុនផលិតគ្រាប់រុក្ខជាតិ (*GM* ) ការពារស្រេបច្បាប់មិនឲ្យក្រុមហ៊ុនដទៃផលិតគ្រាប់រុក្ខជាតិ (*GM* ) នោះទេ។គ្រាប់រុក្ខជាតិមិនអាចតពូជបានទេ គឺត្រូវទិញពូជពីក្រុមហ៊ុនជារៀងរាល់ឆ្នាំ។

IV. លក្ខណៈខុសគ្នានែះ

ក. រុក្ខជាតិម៉ូណូកូទីលេដូន និងរុក្ខជាតិឌីកូទីលេដូនៈ

+ ម៉ូណូកូទីលេដូន
  - គ្រាប់មានកូទីលេដុង១
  - ស្លឹកមានទ្រនុងស្រប
  - ផ្កាមាន៣ស្រទាប់ឬគុណនិង៣
  - ដើមមានបាច់សសៃនាំស្ថិតនៅរាយប៉ាយ
  - ឬសជាឬសស្វៃ។
+ ឌីកូទីលេដូន
  - គ្រាប់មានកូទីលេដុង២
  - ស្លឹកមានទ្រនុងបែកជាខ្នែង
  - ផ្កាមាន៤ស្រទាប់ឬ៥ស្រទាប់
  - ដើមមានបាច់សសៃនាំជារង្វង់
  - ឬសជាឬសកែវ

ខ. ការបង្កាត់ជិត និងការបង្កាត់ឆ្ងាយ

+ ការបង្កាត់ជិត
  - ការបង្កាត់រវាងសត្វដែលចេញពីមេបាមួយគូឬរវាងមេបានិងកូនរបស់វា
  - សណ្ដានក្រោយមានកម្លាំងជិវិតខ្សោយ លទ្ធភាពបន្តពូជថយចុះ បង្កើតភាពមិនប្រក្រតីនៃក្រូម៉ូសូមនាំទៅរកការផុតពូជ
  - អាចបង្កើតនិងរក្សានូវពូជសុទ្ធចំពោះលក្ខណៈដែលគេចង់បាន។
+ ការបង្កាត់ឆ្ងាយ
  - ជាការបង្កាត់រវាងពូជខុសគ្នាឬសែស្រឡាយខុសគ្នាឬប្រភេទខុសគ្នា

- អ៊ីប្រ៊ីតមានកម្លាំងជីវិតខ្លាំងធន់និងជម្ងឺ ឆាប់លូតលាស់ល្អ ផ្តល់ទិន្នផលខ្ពស់
- អារ មិនអាចបង្កកំណើតបាន(ក្នុងករណីមេបាជាប្រភេទខុសគ្នា)

V. ក. អាំងស៊ុយលីនជាអរម៉ូន។

- បើកង្វះអាំងស៊ុយលីនបណ្តាលឲ្យគ្លុយកូសក្នុងឈាមកើនឡើង តម្រង់នោមមិនអាចធ្វើឲ្យគ្លុយកូសទាំងអស់មិនអាចជ្រាបចេញវិញបាន ហើតបញ្ចេញគ្លុយកូសទៅក្នុងទឹកនោម ធ្វើឲ្យទឹកនោមមានបរិមាណគ្លុយកូសច្រើន បង្កឲ្យកើតមានជម្ងឺទឹកនោមផ្អែម។

ខ. របៀបផលិតអរម៉ូនអាំងស៊ុយលីនមាន៤ជំហានៈ

- ជំហានទី1 យកក្រូម៉ូសូមឬ $ADN$ របស់មនុស្សដែលផ្ទុកសែនសំយោគអាំងស៊ុយលីនចេញពីកោសិកាលំពែងរបស់មនុស្ស។ បន្ទាប់មកកាត់យកសែនសំយោគអាំងស៊ុយលីនដោយប្រើអង់ស៊ីមកាត់ (អង់ស៊ីមបង្រួម)។
- ជំហានទី2 យកប្លាស្មីត ($ADN$ បាក់តេរី)ចេញពីបាក់តេរីហើយកាត់យកអង្កត់ $ADN$ ចេញពីប្លាស្មីតដោយអង់ស៊ីមបង្រួម។
- ជំហានទី3 បញ្ចូលសែនរបស់មនុស្សទៅនិងប្លាស្មីតរបស់បាក់តេរីដោយប្រើអង់ស៊ីមភ្ជាប់។រួចយកប្លាស្មីតនេះបញ្ចូលតៅក្នុងបាក់តេរី។
- ជំហានទី4 បាក់តេរីបន្តពូជ បង្កើតបានបាក់តេរីច្រើនធ្វើឲ្យសែនសំយោគអាំងស៊ុយលីនបានកាន់តែច្រើន។ សែននីមួយៗសំយោគប្រូតេអ៊ីនអាំងស៊ុយលីន។

VI. ក. អង់ស៊ីម $ARN$ ប៉ូលីមេរ៉ាសមាននាទីៈ

- ទទួលស្គាល់សញ្ញាណសេនេទិចលើ $ADN$ ដែលចាប់ផ្តើមនិងបញ្ចប់ការសំយោគ $ARN_m$ នៅត្រង់កន្លែងណាមួយជាក់លាក់។
- បើម៉ូលេគុល $ADN$ ផ្តាច់សម្ព័ន្ធអ៊ីដ្រូសែនដែលភ្ជាប់ដោយច្រវ៉ាក់ទាំងពីរ របស់ $ADN$ ។
- ធ្វើឲ្យប៉ូលីមែកម្មនៃរីបូនុយក្លេអូទីត រីបូនុយក្លេអូទីតសេរីចូលមកបំពេញច្រវ៉ាក់នុយក្លេអូទីតម្ខាងរបស់អង្កត់ $ADN$ តាមគោលការណ៍បំពេញបាស(ឬគោលការណ៍ចម្លងក្រម) $A-T$ , $C-G$ ។

ខ. គណនាសមាមាត្រជាភាគរយនៃនុយក្លេអូទីតនីមួយៗរបស់អង្កត់ADN

បម្រាប់ $ARN_m$ មាន

$$A = 4U \,,\ \frac{G}{C} = \frac{1}{2} \,,\ \frac{U}{G} = \frac{1}{5}$$

$$\Rightarrow G = 5U$$

$$C = 2G = 2 \times 5U = 10U$$

$ARNm$ ជាច្រវ៉ាក់ទោល

$A + U + C + G = 100\%$

$4U + U + 10U + 5U = 20U$

$20U = 100\%$

$\Rightarrow U = \frac{50}{20} = 5\%$

$A = 4 \times 5\% = 20\%$

$G = 5 \times 5\% = 25\%$

$C = 10 \times 5\% = 50\%$

តាមគោលការណ៍ចម្លងក្រម

$\%A = \%T = \frac{(A + U)_{ARNm}}{2} = \frac{20 + 5}{2} = 12.5\%$

$\%C = \%G = \frac{(C + G)_{ARNm}}{2} = \frac{50\% + 25\%}{2} = 37.5\%$

**ដូចនេះ** $\%A = \%T = 12.5\%$
$\%C = \%G = 37.5\%$

VII. ក. គណនាចំនួននុយទីតប្រភេទនីមួយៗរបស់ម៉ូលេគុលADN

បម្រាប់ $C = 35\%$
$C - A = 4400$

តាមគោលការណ៍បំពេញបាស

$A - T\ , C - G \quad \Rightarrow A = T\ , C = G$

$\%A + \%T + \%C + \%G = 100\%$

$2A + 2C = 100\%$

$A\% + \%C = 50\%$

$\Rightarrow \%A = 50\% - \%C = 50\% - 35\% = 15\%$

តាម $C - A = 4400$ នុយក្លេអូទីត

$\frac{35M}{100} - \frac{15M}{100} = 4400$

$\frac{20M}{100} = 4400 \Rightarrow M = \frac{440000}{20} = 22000$

$A = \frac{15 \times 22000}{100} = 3300$ នុយក្លេអូទីត

$C = \frac{35 \times 22000}{100} = 7700$ នុយក្លេអូទីត

**ដូចនេះ** $A = T = 3300$ នុយក្លេអូទីត

$C = G = 7700$ នុយក្លេអូទីត

ខ. គណនាចំនួនជំហានរបស់ $ADN$

ដោយ1 ជំហាន=10 គូបាស=20 នុយក្លេអូទីត

តាមចំនួនជំហាន $= \frac{M}{20} = \frac{22000}{20} = 1100$ ជំហាន

**ដូចនេះ** $ADN$ មាន 110 ជំហាន

គ. រកចំនួននុយក្លអូទីតសេរី

$ADN$ ស្វ័យតម្លើងទ្វេ 1លើកបាន$ADN$ កូន $2^1$

$ADN$ ស្វ័យតម្លើងទ្វេ 2លើកបានADN កូន $2^2$

$ADN$ ស្វ័យតម្លើងទ្វេ 3លើកបានADN កូន $2^3$

……………………………………………………………

$ADN$ ស្វ័យតម្លើងទ្វេ nលើកបាន$ADN$ កូន $2^n$

ដោយ $ADN$ ស្វ័យតម្លើងទ្វេ៤លើកបាន$ADN$ កូន$2^4$

ក្នុងនោះមាន $ADN$ មេ1 គេបាន$ADN$ កើតថ្មី $2^4 - 1 = 16 - 1 = 15$

$M' = M \times 15 = 22000 \times 15 = 33 \times 10^4$ នុយក្លេអូទីតសេរី

**ដូចនេះ** នុយក្លេអូទីត $\boxed{M' = 33 \times 10^4}$

| | |
|---|---|
| **ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**................................... |
| **សម័យប្រឡង ១៩ សីហា ២០១៩** | **មណ្ឌលប្រឡង**.................................. |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**............. |
| **រយៈពេល៖ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**..................................... |
| | **ហត្ថលេខាបេក្ខជន**........................... |

## ប្រធាន

I. ដូចម្តេចដែលហៅថាដំណើរលម្អងសិប្បនិម្មិត? ហេតុអ្វីបានជាគេធ្វើដំណើរលម្អងសិប្បនិម្មិត?

II. ចូរពន្យល់ពី

ក. ដំណើរឆ្លងកាត់ស៊ីណាប់របស់អាំងភ្លុចប្រសាទ។

ខ. ការកកើតនៃពុម្ពក្រៅ?

III. ចូរពណ៌នាពីលក្ខណៈរបស់អង់ស៊ីម ?

IV. តើអរម៉ូនដែលបញ្ចេញដោយកោសិកា ($\beta$) និងកោសិកា ($\alpha$) របស់លំពែងដែលមានសកម្មភាពដូចម្តេចខ្លះ?

V. ចូរប្រៀបធៀប $ADN$ និងប្រូតេអ៊ីន។

VI. ម៉ូលេគុល $ADN$ មួយមានចំនួនវង្វេល $10^5$ ។ ដោយការនៃផលសងនុយក្លេអូទីត $A$ និងនុយក្លេអូទីត $C$ ស្មើ $4\times10^{10}$ ។

ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ $ADN$

ខ. តើ $ADN$ នេះស្វ័យតម្លើងទ្វេប៉ុន្មានលើក?បើក្រោយស្វ័យតម្លើងទ្វេរួច $ADN$ មាននុយក្លេអូទីត$A$ ស្មើ $48\times10^5$

VII. ច្រវ៉ាក់ម្ខាងនៃសែនមួយមាននុយក្លេអូទីត$C=\frac{1}{2}$ ,$A=\frac{1}{3}$ ,$T=\frac{1}{6}$ ។ $ARN_m$ មួយចម្លងក្រមចេញពីច្រវ៉ាក់ម្ខាងនៃសែននេះមានរីបូនុយក្លេអូទីត 750 ។

ក. រកចំនួនរីបូនុយក្លេអូទីតនៃរាល់ប្រភេទរបស់ $ARN_m$ នេះ។

ខ. រកចំនួនសម្ព័ន្ធអ៊ីដ្រូសែននៃសែនខាងលើ។

# អត្រារកំណែ

I. + ដំណើរលម្អងសិប្បនិម្មិត ជាដំណើរលម្អងដែលមនុស្សយកគ្រាប់លម្អងពីរុក្ខជាតិមួយទៅដាក់លើស្ទិចម៉ាតនៃរុក្ខជាតិមួយទៀត។

+ មនុស្សធ្វើដំណើរលម្អងសិប្បនិម្មិតដើម្បីបង្កាត់រុក្ខជាតិមានលក្ខណះពិសេសដែលគេចង់បាន។

II. ក. ដំណើរឆ្លងកាត់ស៊ីណាប់របស់អាំងភ្លុចប្រសាទនៅចុងអាក់សូនមានថង់តូចៗជាច្រើនដែលផ្ទុកសារជាតុ( ណឺរ៉ូនបញ្ជូនសារ ឬ ពពុះតូចៗ )។ពេលអាំងភ្លុចប្រសាទទៅដល់ចុងអាក់សូនថង់តូចៗទាំងនោះក៏ផ្ទុះបែកហើយបញ្ចេញណឺរ៉ូនបញ្ជូនសារសោយឆ្លងកាត់ស៊ីណាប់។បន្ទាប់មកណឺរ៉ូនបញ្ជូនសារនេះ បង្កើតអាំងភ្លុចប្រសាទថ្មីទៅក្នុងដង់ឌ្រីតរបស់ណឺរ៉ូនបន្ទាប់រួចធ្វើដំណើរតាមតួកោសិកា និងចុះតាមអាក់សូនរហូតដល់ចុងអាក់សូន។

ខ. ការកើតពុម្ពក្រៅ កកើតនៅពេលសារពាង្គកាយកប់ក្នុងកម្ទេចកំណត្រូវរលាយបន្តិចម្តងៗហើយបន្សល់ទុកនូវពុម្ពទទេដែលមានទម្រង់ដូចសារពាង្គកាយ។ ពុម្ពទទេនេះជាពុម្ពក្រៅ។ ឬនៅពេលដែលភាវៈរស់បានងាប់បានធ្លាក់ទៅបាតទឹកឬបាតសមុទ្រ ទឹកហូរនាំសិលាកម្ទេចកំណគ្របដណ្តប់លើសាកសពនោះ។ សាកសពរលួយបែកជាតុហើយបន្សល់ទុកតែរូបរាងដែលបង្ហាញពីរូបរាងរបស់ភាវៈរស់នោះ។នេះជាពុម្ពក្រៅ។

III. ពណ៌នាពីលក្ខណះរបស់អង់ស៊ីមះ

- អង់ស៊ីមទាំងអស់ជាប្រូតេអ៊ីនដែលមានអំពើយថាប្រភេទ
- អង់ស៊ីមមានសភាពខ្លាំងក្លា។ គឺអង់ស៊ីមមួយចំនួនតូចអាចបង្កើនល្បឿនប្រតិកម្មមួយចំនួនធំ។
- អង់ស៊ីមប្រែប្រួលទម្រង់និងតួនាទីទៅតាមសីតុណ្ហភាព ឥទ្ធិពល $pH$ និងកំហាប់ស៊ុបស្រ្តាត។
- អង់ស៊ីមជាកតាលីករដែលមានប្រតិកម្មបញ្ច្រាសទៅវិញទៅមក។
- អង់ស៊ីមខ្លះត្រូវការកូអង់ស៊ីម។

IV. + សកម្មភាពអរម៉ូនដែលបញ្ចេញដោយកោសិកាបេតា($\beta$) នៅពេលកម្រិតគ្លុយកូសឡើងខ្ពស់នៅក្នុងឈាមកោសិកាបេតា($\beta$) របស់លំពែងត្រូវបានភ្ញោចរួចបញ្ចេញអរម៉ូនអាំងស៊ុយលីនចូលទៅក្នុងចរន្តឈាមទៅភ្ញោចកោសិកាគោលដៅមានដូចជាថ្លើម កោសិកាសាច់ដុំជាប់ឆ្អឹង និងជាលិកាខ្លាញ់ចាប់យកគ្លុយកូសប្រើប្រាស់ជាប្រភពថាមពលសកម្មភាពផ្សេងៗ។ គ្លុយកូសដែលនៅសល់បម្លែងទៅជាគ្លីកូសែនស្តុកទុកទៅក្នុងថ្លើមនិងសាច់ដុំជាប់នឹងឆ្អឹង។ ម្យ៉ាងទៀតគ្លុយកូសត្រូវប្លែងជាខ្លាញ់ហើយស្តុកទុកក្នុងជាលិកាខ្លាញ់។

+ សកម្មភាពអរម៉ូនដែលបញ្ចេញដោយកោសិកា ($\alpha$) នៅពេលដែលកំហាប់គ្លុយកូសនៅក្នុងឈាមធ្លាក់ចុះក្រោមកម្រិតកំណត់ កោសិកា ($\alpha$) របស់លំពែងត្រូវបានភ្ញោចឲ្យបញ្ចេញអរម៉ូន

គ្លុយកាកុងទៅក្លោចកោសិកាគោលដៅឲ្យផលិតគ្លុយកូស ។ក្នុងថ្លើមគ្លុយកាកុងបម្លែងគ្លីកូសែនឲ្យជាគ្លុយកូសសាយចូលទៅក្នុងចរន្តឈាម។គ្លុយកាកុងធ្វើឲ្យអាស៊ីតអាមីនេ និងអាស៊ីតខ្លាញ់ប្លែងទៅជាគ្លុយកូសវិញ។

V. ប្រៀបធៀប $ADN$ និងប្រូតេអ៊ីន

\+ លក្ខណៈដូច

- ជាម៉ាក្រូម៉ូលេគុល
- ម៉ូលេគុលនីមួយៗជាច្រវ៉ាក់ម៉ូលេគុលដែលកើតពីឯកតានៃជាតុបង្ក(ម៉ូលេគុល)
- ម៉ូលេគុលនីមួយមានតំណលំដាប់នុយក្លេអូទីតឬតំណលំដាប់អាស៊ីតអាមីនេជាក់លាក់។

\+ លក្ខណៈខុសគ្នា

$ADN$

- ម៉ូណូមែគឺនុយក្លេអូទីត
- កើតចេញពីច្រវ៉ាក់២ខ្សែ
- នុយក្លេអូទីត៣កំណត់អាស៊ីតអាមីនេ១
- តំណលំដាប់នុយក្លេអូទីតកំណត់តំណលំដាប់អាស៊ីតអាមីនេ
- បង្កពីនុយក្លេអូទីត៤ប្រភេទ

ប្រូតេអ៊ីន

- ម៉ូណូមែគឺអាស៊ីតអាមីនេ
- កើតពីច្រវ៉ាក់អាស៊ីតអាមីនេទោល
- អាស៊ីតអាមីនេ១កំណត់នុយក្លេអូទីត៣
- តំណលំដាប់អាស៊ីតអាមីនេកំណត់តំណលំដាប់នុយក្លេអូទីត
- បង្កអាស៊ីតអាមីនេ២០ប្រភេទ។

VI. ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ $ADN$

បម្រាប់ $ADN$ មាន $10^5$ រង្វេល

$$\left(A - C\right)^2 = 4 \times 10^{10}$$

$A_{កូន} = 48 \times 10^5$ នុយក្លេអូទីត

ដោយ 1 រង្វេលជុំ $= 20$ នុយក្លេអូទីត

$M =$ ចំនួនរង្វេល $\times 20$

$= 20 \times 10^5$ នុយក្លេអូទីត

តាមគោលការណ៍បំពេញបាស

$A - T\ ,C - G \Rightarrow A = T\ ,C = G$

$M = A + T + C + G = 2A + 2C$

$M = 2(A - C) =$

$A - C = \dfrac{M}{2}$

$A = \dfrac{M}{2} - C$

$A + C = 10^5 \quad (1)$

ដោយ $A - C = 2 \times 10^5 \quad (2)$

តាម (1) និង (2) យើងបាន

$$\begin{cases} A - C = 2 \times 10^5 & (2) \\ A + C = 10 \times 10^5 & (1) \end{cases}$$

$2A = 12 \times 10^5$

$A = 6 \times 10^5$

$(1) \Rightarrow A + C = 10 \times 10^5 - 6 \times 10^5 = 4 \times 10^5$

**ដូចនេះ** $A = T = 6 \times 10^5$ នុយក្លេអូទីត

$C = G = 6 \times 10^5$ នុយក្លេអូទីត

ខ. គណនាចំនួនដងនៃការស្វ័យតម្លើងទ្វេរបស់ $ADN$

បម្រាប់ $A_{\text{កូន}} = 48 \times 10^5$ នុយក្លេអូទីត

$ADN$ ស្វ័យតម្លើងទ្វេ 1លើកបាន$ADN$ កូន $2^1$

$ADN$ ស្វ័យតម្លើងទ្វេ 2លើកបាន$ADN$ កូន $2^2$

$ADN$ ស្វ័យតម្លើងទ្វេ 3លើកបាន$ADN$ កូន $2^3$

……………………………………………………………

$ADN$ ស្វ័យតម្លើងទ្វេ nលើកបាន$ADN$ កូន $2^n$

$A_{\text{សែន}} = A \times 2^n \Rightarrow 2^2 = \dfrac{A_{\text{កូន}}}{A} = \dfrac{48 \times 10^5}{6 \times 10^5}$

$2^n = 8$

$2^n = 2^3$

$\Rightarrow n = 3$

**ដូចនេះ** $ADN$ ស្វ័យតម្លើងទ្វេ 3 ដង

VII. ក. គណនាចំនួនរីបូនុយក្លេអូទីតប្រភេទនីមួយៗរបស់ $ARN_m$

បម្រាប់ $C_1 = \frac{1}{2}$ នៃ $\frac{M}{2} = \frac{M}{2} \times \frac{1}{2}$

$A_1 = \frac{1}{3}$ នៃ $\frac{M}{2} = \frac{M}{2} \times \frac{1}{3}$

$T_1 = \frac{1}{6} = \frac{M}{2} \times \frac{1}{6}$

$m = 750$ រីបូនុយក្លេអូទីត

ដោយម៉ូលេគុល$ARNm$ សំយោគចេញពីច្រវ៉ាក់ម្ខាងរបស់សែន

$m = \frac{M}{2} = 750$ រីបូនុយក្លេអូទីត

$C_1 = \frac{1}{2} \times 750 = 375$ នុយក្លេអូទីត

$A_1 = \frac{1}{3} \times 750 = 250$ នុយក្លេអូទីត

$T_1 = \frac{1}{6} \times 750 = 125$ នុយក្លេអូទីត

ដោយ$\frac{M}{2} = A_1 + T_1 + C_1 + G_1$

$$\Rightarrow G_1 = \frac{M}{2} - (A_1 + T_1 + C_1)$$
$$= 750 - (250 + 125 + 375)$$
$$= 0$$

ដោយ $ARNm$ សំយោគចេញពីច្រវ៉ាក់ម្ខាងរបស់សែន

តាមគោលការណ៍បំពេញបាស ឬចម្លងក្រម

$A - U, T - A, C - G$

$A_1 = U_{ARNm} = 250$ រីបូនុយក្លេអូទីត

$T_1 = A_{ARNm} = 125$ រីបូនុយក្លេអូទីត

$C_1 = G_{ARNm} = 375$ រីបូនុយក្លេអូទីត

**ដូចនេះ** $U_{ARNm} = 250$ រីបូនុយក្លេអូទីត

$A_{ARNm} = 125$ រីបូនុយក្លេអូទីត

$G_{ARNm} = 375$ រីបូនុយក្លេអូទីត

ខ. គណនាចំនួនសម្ព័ន្ធអ៊ីដ្រូសែនរបស់សែន
តាមគោលការណ៍ចម្លងក្រម

A<sub></sub>សែន = Tសែន $= (A + T)_{ARNm} = 125 + 250 = 375$ នុយក្លេអូទីត

Cសែន = Gសែន = $(C + G)_{ARNm} = 0 + 375 = 375$ នុយក្លេអូទីត

ដោយ $A$ ភ្ជាប់ $T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 2

ដោយ $C$ ភ្ជាប់ $G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 3

$L_H = 2A + 3C = 2(235) + 3(375) = 1875$ សម្ព័ន្ធអ៊ីដ្រូសែន

**ដូចនេះ** $L_H = 1875$ សម្ព័ន្ធអ៊ីដ្រូសែន

# វិញ្ញាសាសំរាប់បង្រៀន

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**................................ |
| **សម័យប្រឡង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**................................ |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**.................................... |
| | **ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. តើប្រូតេអ៊ីនមាននាទីដូចម្តេចខ្លះ ?

II. គេចែកប្រូតេអ៊ីនជាប៉ុន្មានក្រុម ? ចូរបកស្រាយ ?

III. ហេតុអ្វីបានជានៅពេលក្តៅខ្លាំង ប្រតិកម្មគីមីប្រព្រឹត្តទៅបានលឿន ?

IV. តើគេហៅអង់ស៊ីមយ៉ាងដូចម្តេច ? ចូរឲឈ្មោះអង់ស៊ីម និង ស៊ុបស្ត្រាតឲបាន 5 ។

V. តើគេចែកអង់ស៊ីមជាប៉ុន្មានក្រុម ? អ្វីខ្លះ ?

VI. ម៉ូលេគុល ADN មួយមាននុយក្លេអូទីតប្រភេទ A = 14% នៃចំនួននុយក្លេអូទីតសរុប ។ ក្នុងម៉ូលេគុល ADN នេះ មាននុយក្លេអូទីតប្រភេទ C ចំនួន 4400 លើសនុយក្លេអូទីតប្រភេទ A ។

ក. ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗ ។

ខ. តើម៉ូលេគុល ADN មានប៉ុន្មានវង្វេលជុំ ?

គ. ចូររកចំនួនសម្ពន្ធ័អ៊ីដ្រូសែនរវាង A និង T ហើយ C និង G ?

VII. ម៉ាស់ម៉ូលេគុលនៃប្រភេទប្រូតេអ៊ីនមួយគឺមាន 13860 ហើយអាស៊ីតអាមីនេមួយមានម៉ាសម៉ូលេគុលប្រហែល 110 ឌ្នាតកាបូន ។

ក. តើសែនដែលកំណត់សំយោគម៉ូលេគុលប្រូតេអ៊ីននេះមានប្រវែងប៉ុន្មាន ?

ខ. តើម៉ូលេគុល $ARN_m$ នាំសារដែលចូលរួមសំយោគប្រតេអ៊ីនខាងលើត្រូវមានត្រីធាតុចម្លងក្រមប៉ុន្មាន ?

គ. តើមាន $ARN_t$ ដឹកនាំត្រូវចូលទៅក្នុងរីបូសូមប៉ុន្មានដង ដើម្បីចូលរួមសំយោគម៉ូលេគុលប្រូតេអ៊ីន ?

# អត្រាកំណែ

I. ប្រូតេអ៊ីនជាកាតាលិករ ជាអរម៉ូន ជាអង់ទីករ ជាប្រតេអ៊ីនទំរង់ ជាអ្នកដឹកនាំ និងជាអ្នកធ្វើចលនា។

II. គេចែកប្រូតេអ៊ីនជាពីរក្រុម គឺ ប្រូតេអ៊ីនសរសៃ និង ប្រូតេអ៊ីនគ្រាប់ ។

+ ប្រូតេអ៊ីនសរសៃ មាននាទីជាអ្នកការពារ វាជាម៉ូលេគុលវែងៗស្ថិតមិនរលាយក្នុងទឹក ។ ឧទាហរណ៍ ស្បែក សក់ ក្រចក ... ។

+ ប្រូតេអ៊ីនគ្រាប់ មាននាទីជាចលករ ជាម៉ូលេគុលមានរាងមូលតូចៗរលាយនៅក្នុងទឹក ។ ឧទាហរណ៍ អង់ទីករ អេម៉ូក្លូប៊ីន និង អាល់ប៊ុយមីន ... ។

III. បានជានៅពេលក្តៅខ្លាំងប្រតិកម្មគីមីប្រព្រឹត្តទៅបានលឿនព្រោះ ចលនានៃការប៉ះទង្គិចរបស់ម៉ូលេគុលក៏វាមានការកើនឡើងដែរ ។

IV. គេអាចហៅអង់ស៊ីមផ្តើមដោយស៊ុបស្ត្រាតហើយបញ្ចប់ដោយពាក្យ (អាស)

| | |
|---|---|
| + ស៊ុបស្ត្រាត | + អង់ស៊ីម |
| _ អាមីដុង | _ អាមីឡាស |
| _ លីពិត | _ លីប៉ាស |
| _ ប្រូតេអ៊ីន | _ ប្រតេអាស |
| _ ផូស្វាត | _ ផូស្វាតាស |
| _ សែលុយឡូស | _ សែលុយឡាស |

V. គេចែកអង់ស៊ីមជាប្រាំមួយក្រុមគឺ ត្រង់ស្វែរ៉ាស , អុកស៊ីដូរេដុកតាស , អ៊ីដ្រូឡាស , លីយ៉ាស , លីហ្គាស និង អ៊ីដ្រុកស៊ីឡាស ។

VI. ក. គណនានុយក្លេអូទីតប្រភេទនិមួយៗ

តាមគោលការណ៍ បំពេញគ្នានៃគូបាសនីទ្រីច A-T នាំឲ A=T , C-G នាំឲ C=G

<u>បំរាប់</u> A= 14%

ដោយ A+C= 50%

នាំអោយ C= 50% - 14% = 36%

C= A + 4400 ( 1 )

+ រកនុយក្លេអូទីតរបស់ A

A = $\frac{M \times \%A}{100}$ (2)

+ រកនុយក្លេអូទីតរបស់ C

C = $\frac{M \times \%C}{100}$ (3)

យក (2) និង (3) ជួសក្នុង(1)

នាំអោយ $\frac{M \times \%A}{100} - \frac{M \times \%C}{100}$ = 4400

$\frac{M \times 36}{100} - \frac{M \times 14}{100}$ = 4400

36M – 14M = 440000

22M = 440000

M = $\frac{440000}{22}$ = 20000 នុយក្លេអូទីត

នាំអោយ A = $\frac{20000 \times 14}{100}$ = 2800 នុយក្លេអូទីត

C = $\frac{20000 \times 36}{100}$ = 7200 នុយក្លេអូទីត

**ដូចនេះ**

| |
|---|
| A=T= 2800 នុយក្លេអូទីត |
| C=G= 7200 នុយក្លេអូទីត |

ខ. គណនារង្វេលជុំ

ដោយ មួយរង្វេលជុំស្មើ 10 គូ ស្មើនិង 20 នុយក្លេអូទីត

នាំអោយ ចំនួនរង្វេលជុំ = $\frac{M}{20}$

= $\frac{20000}{20}$ = 1000 រង្វេលជុំ

**ដូចនេះ** ចំនួនរង្វេលជុំរបស់ADN ស្មើ 1000 រង្វេលជុំ

គ. គណនាសម្ពន្ធ័អ៊ីដ្រូសែន

ដោយ A ភ្ជាប់ដោយ T សម្ពន្ធ័ 2

C ភ្ជាប់ដោយ G សម្ពន្ធ័ 3

នាំអោយ L = 2A + 3C

$= (2\times 2800) + (3 \times 7200)$

= 5600 + 21600

= 27200 សម្ពន្ធ័អ៊ីដ្រូសែន

**<u>ដូចនេះ</u>** សម្ពន្ធ័អ៊ីដ្រូសែនស្មើ 27200 សម្ពន្ធ័អ៊ីដ្រូសែន

VII. ក. គណនាប្រវែងរបស់សែន

ដោយ នុយក្លេអូទីតមួយៗមានប្រវែង 0.34nm → l = $\frac{M}{2} \times 0.34nm$

<u>បំរាប់</u> ម៉ាសម៉ូលេគុល ប្រូតេអ៊ីនសរុប 13860

ម៉ាស aa មួយ មាន 110 ខ្នាតកាបូន

+ រកអាស៊ីតអាមីនេ

13860 ÷ 110 = 126

+ រកកូដុង

កូដុងមានពីរគឺ កូដុងផ្តើម និង កូដុងស្តប់

126 + 2 = 128

+ រករីបូនុយក្លេអូទីត

ដោយ នុយក្លេអូទីតបីតគ្នាជាក្រុមអាស៊ីតអាមីនេមួយ

128 × 3 = 384 រីបូនុយក្លេអូទីត

+ រកនុយក្លេអូទីត

ដោយ M = m × 2

= 384 × 2 = 768 នុយក្លេអូទីត

នាំអោយ l = $\frac{768}{2} \times 0.34nm$ = 130,56 nm

**<u>ដូចនេះ</u>** ប្រវែងរបស់សែនស្មើ 130,56 nm

ខ. គណនាចំនួនត្រីជាតុម៉ូលេគុល $ARN_m$ ចូលរួមសំយោគប្រូតេអ៊ីន

តាមរូបមន្ត $\frac{m}{3} = \frac{384}{3} = 128$ ត្រីជាតុ

<u>ដូចនេះ</u> $ARN_m$ ដែលចូលរួមសំយោគប្រូតេអ៊ីនមានចំនួន 128 ត្រីជាតុ

គ. គណនាចំនួន $ARN_t$ ដឹកនាំចូលរីបូសូម

ដោយ $ARN_t$ មួយដឹកនាំអាស៊ីតអាមីនេមួយ

→ចំនួន $ARN_t$ = កូដុង - 1

= 128 – 1 = 127

<u>**ដូចនេះ**</u> ចំនួន $ARN_t$ ដឹកនាំចូលរីបូសូមមានចំនួន 127ដង

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**................................ |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ: ៧៥** | **ឈ្មោះបេក្ខជ**.................................... |
| | **ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. តើនៅលើតម្រងនោមមនុស្សមានក្រពេញប៉ុន្មាន? មានទម្ងន់ប៉ុន្មាន?

II. វេណាំងគឺជាអ្វី?

III. តើក្រពេញខួរនៅលើតម្រងនោមមានមុខងារអ្វីខ្លះ?

IV. តើចែកក្រពេញនីមួយៗជាប៉ុន្មានផ្នែក? អ្វីខ្លះ?

V. លំពែងជាអ្វី? មាននាទីដូចម្តេច? ហេតុអ្វីបានជាវាជាក្រពេញអង់ដូគ្រីនផង និង ជាក្រពេញអិចសូគ្រីនផង?

VI. ម៉ូលេគុល ADN មួយនៅពេលស្វ័យតំឡើងទ្វេ 4 ដង ត្រូវការនុយក្លេអូទីតសេរីប្រភេទ T =5250 ។ នៅលើអង្គត់ ADN នេះនុយក្លេអូទីតប្រភេទ C និង A មានសមាមាត្ររៀងគ្នា 8 និង 7 ។

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ ADN ?

ខ. គណនាចំនួនសម្ពន្ធ័គីមីប្រវាក់ម្ខាងរបស់ ADN ?

គ. តើមាន $ARN_t$ ប៉ុន្មានចូលទៅកាន់រីបូសូម ?

VII. សែនមួយមាននុយក្លេអូទីតប្រភេទ C ច្រើនជាងនុយក្លេអូទីតប្រភេទ A ចំនួន 360 ។ ម៉ូលេគុល $ARN_m$សំយោគចេញពីសែននេះមានរីបូនុយក្លេអូទីត A,U,C,G តាមសមាមាត្រគឺ $A = \frac{1}{10}, U = \frac{2}{10}, C = \frac{3}{10}, G = \frac{4}{10}$ នៃចំនួនរីបូនុយក្លេអូទីតទាំងអស់ ។

ក. គណនាចំនួនរីបូនុយក្លេអូទីតប្រភេទនីមួយៗរបស់ $ARN_m$ ?

ខ. គណនាចំនួនចំនួនសម្ពន្ធ័អ៊ីដ្រូសែនសរុប ?

គ. ចូររកម៉ាសម៉ូលេគុលប្រូតេអ៊ីនមួយ បើអាស៊ីតអាមីនេមួយមានម៉ាសជាមធ្យម 110 ខ្នាតកាបូន ?

# អត្រាកំណែ

I. ក្រពេញលើតម្រង់នោមមាន ២ផ្នែកគឺៈ ផ្នែកខាងក្រៅ ជាក្រពេញករទិចលើតម្រង់នោម និង ផ្នែកខាងក្នុង ជាក្រពេញខួរលើតម្រង់នោម ។ផ្នែកនីមួយៗផលិតអរម៉ូនដូចជា ៖ ក្រពេញករទិចលើតម្រង់នោម ផលិតអរម៉ូនករទីលសូល និងអរម៉ូនអាល់ដូស្តេរ៉ូន។ក្រពេញខួរលើតម្រង់នោម ផលិតអរម៉ូនអេឌីណេព្រីនឬអរម៉ូនដាល់ដូស្តេរ៉ូន។ក្រពេញលើតម្រងនោមនិមួយៗ មានទម្ងន់ប្រហែល ១២ gហើយលក្ខណៈពិសេសរបស់វាគឺសម្បូរទៅដោយបណ្តាញសរសៃឈាម ។ ក្រពេញនេះបង្កឡើងពីជាលិកា២ ប្រភេទខុសគ្នាដែលជាហេតុនាំឲគេចែកប្រភេទនៃក្រពេញនិមួយៗជា២ ផ្នែក ។

II. រេណាំង ជាអង់ស៊ីមដែលបម្លែងប្រូតេអ៊ីនប្លាស្មាអង់ស៊ីយូតង់ស៊ីណូសែនឲទៅជាអង់ស៊ីយូតង់ស៊ីនដែលបន្ទាប់មកក្លាយជាអង់ស៊ីយូតង់ស៊ីន II នៅក្នុងសួត ។ ដំណើរខាងលើនេះ ហៅថាប្រព័ន្ធអង់ស៊ីយូតង់ស៊ីនអាល់ដូស្តេរ៉ូន ។

III. ក្រពេញខួរលើតម្រង់នោម ផលិតអរម៉ូនអេឌីណេព្រីនឬអរម៉ូនដាល់ដូស្តេរ៉ូន។ក្រពេញលើតម្រងនោមនិមួយៗ មានទម្ងន់ប្រហែល ១២ gហើយលក្ខណៈពិសេសរបស់វាគឺសម្បូរទៅដោយបណ្តាញសរសៃឈាម ។ ក្រពេញនេះបង្កឡើងពីជាលិកា២ ប្រភេទខុសគ្នាដែលជាហេតុនាំឲគេចែកប្រភេទនៃក្រពេញនិមួយៗជា២ ផ្នែក ។

IV. គេចែក ក្រពេញជា២ផ្នែក គឺក្រពេញអ៊ិចសូគ្រីន និង ក្រពេញអង់ដូគ្រីន។

V. លំពែង ជាសរីរាង្គមួយវែងសណ្តូកទទឹងទៅក្នុងពោះវៀនតូចគឺនៅចន្លោះតម្រង់ នោមនិងនៅលើពោះវៀនតូចក្រោមក្រពះ ។ វាមានផលិតផល ២ ប្រភេទគឺ រស រំលាយអាហារ និង អរម៉ូន ២ ប្រភេទដែលផលិតដោយកោសិកា ១ក្រុមឈ្មោះថាអ៊ីឡូឡង់សេរ៉ង់នៃលំពែង។លំពែងជាក្រពេញចម្រុះគឺ ជាប្រភេទ ក្រពេញអង់ដូគ្រីន ផង និង អិចសូគ្រីន ផង ។បានជាគេនិយាយថាលំពែងជាក្រពេញអង់ដូគ្រីនផង និង អ៊ិចសូគ្រីនផងព្រោះ ៖

- ជាក្រពេញអង់ដូគ្រីន លំពែងបានបញ្ចេញអរម៉ូនទៅក្នុងចរន្តឈាមដោយផ្ទាល់ហើយវាមានអំពើទៅលើមេតាប៉ូលីសគ្លុយកូស។
- ជាក្រពេញអ៊ិចសូគ្រិន លំពែងបានបញ្ចេញរសរំលាយអាហារនៅក្នុងបំពង់លំពែង។

VI. ក. គណនានុយក្លេអូទីតប្រភេទនិមួយៗ

តាមគោលការណ៍ បំពេញគ្នានៃគូបាសនីទ្រីច A-T នាំឲ A=T , C-G នាំឲ C=G

<u>បំរាប់</u> $T^{`} = 5250$ , n= 4 , $\frac{C}{A} = \frac{8}{7}$

<u>ជាទូទៅ</u>

ADN មេ 1 ស្វ័យតំឡើងទ្វេរ 1 ដង →ADN កូន $2^1$

ស្វ័យតំឡើងទ្វេរ 2 ដង →ADN កូន $2^2$

ស្វ័យតំឡើងទ្វេរ 3 ដង →ADN កូន $2^3$

↓ ↓

ស្វ័យតំឡើងទ្វេរ n ដង →ADN កូន $2^n$

ដោយ ADN មេ 1 ស្វ័យតំឡើងទ្វេរ 4 ដង →ADN កូន $2^4$

$\rightarrow T` = T(2^n - 1) = 15T$

$\rightarrow T = \frac{T`}{15} = \frac{5250}{15} = 350$ នុយក្លេអូទីត

+ រកនុយក្លេអូទីតប្រភេទ C

$$\rightarrow \frac{C}{A} = \frac{8}{7}$$

$$\rightarrow C = \frac{8A}{7}$$

ដោយ T = A = 350

$$\rightarrow C = \frac{8 \times 350}{7} = 400$$

**ដូចនេះ**

| |
|---|
| A=T = 350 នុយក្លេអូទីត |
| C=G = 400 នុយក្លេអូទីត |

ខ. គណនាសម្ពន្ធ័គីមីប្រវ៉ាក់ម្ខាង

ដោយ អាស៊ីតអាមមីនេ ភ្ជាប់អាស៊ីតអាមីនេមួយទៀតបានដោយសារសម្ពន្ធ័គីមី

→ សម្ពន្ធ័គីមីប្រវ៉ាក់ម្ខាង m-1

ដោយ m = A + C

= 350 + 400

= 750 រីបូនុយក្លេអូទីត

នាំអោយ 750 – 1 = 749 សម្ពន្ធ័គីមី

**ដូចនេះ** សម្ពន្ធ័គីមីប្រវ៉ាក់ម្ខាងស្មើ 749 សម្ពន្ធ័គីមី

គ. គណនាចំនួន $ARN_t$ ចូលទៅកាន់រីបូសូម

ដោយ $ARN_t$ ដឹកនាំអាស៊ីតអាមីនេមួយ

+ រកចំនួនកូដុង

ដោយនុយក្លេអូទីតបីតគ្នាជាក្រុមអាស៊ីតអាមីនេមួយ

→ 750 ៖ 3 = 250 កូដុង

ដោយ $ARN_t$ = កូដុង - 1

= 250 – 1

= 249 $ARN_t$

**ដូចនេះ** ចំនួន $ARN_t$ ដែលចូលទៅកាន់រីបូសូមមានចំនួន **249 $ARN_t$**

VII. ក. គណនារីបូនុយក្លេអូទីតប្រភេទនិមួយៗរបស់ $ARN_m$

តាមគោលការណ៍បំពេញគ្នានៃគូបាសនីទ្រីច

A - U តែ A ≠ U

C - G តែ C ≠ G

<u>បំរាប់</u> C= A + 360

→ C – A = 360 (1)

សមាមាត្រ $A = \frac{1}{10}m, U = \frac{2}{10}m, C = \frac{3}{10}m, G = \frac{4}{10}m$

+ រករីបូនុយក្លេអូទីត

តាមបំណាកប្រែក្រុម

$(A=T)_{ស៊ែន} = (A+U)_{ARN_m}$

$= \frac{1}{10} + \frac{2}{10} = \frac{3}{10}m$ (2)

$(C=G)_{ស៊ែន} = (C+G)_{ARN_m}$

$= \frac{3}{10} + \frac{4}{10} = \frac{7}{10}m$ (3)

យក (2) និង (3) ជួសក្នុង (1)

$\rightarrow \frac{7}{10}m - \frac{3}{10}m = 360$

4m = 3600

$\rightarrow \quad m = \frac{3600}{4} = 900$

នាំអោយ $A = \frac{1}{10} \times 900 \rightarrow A = 90$

$U = \frac{2}{10} \times 900 \rightarrow U = 180$

$C = \frac{3}{10} \times 900 \rightarrow C = 270$

$G = \frac{4}{10} \times 900 \rightarrow G = 360$

**ដូចនេះ:**

| | |
|---|---|
| A= 90 រីបូនុយក្លេអូទីត | , U= 270 រីបូនុយក្លេអូទីត |
| C= 180 រីបូនុយក្លេអូទីត | , G= 360 រីបូនុយក្លេអូទីត |

ខ. គណនាចំនួនសម្ព័ន្ធអ៊ីដ្រូសែន

វាង A ភ្ជាប់ដោយ T សម្ព័ន្ធ 2

C ភ្ជាប់ដោយ G សម្ព័ន្ធ 3

នាំអោយ L = 2A + 3C

តាមបំណាកប្រែក្រម

$(A=T)_{\text{សែន}} = (A+U)_{ARN_m}$

= 90 + 180

= 270

$(C=G)_{\text{សែន}} = (C+G)_{ARN_m}$

= 270 + 360

= 630

$\rightarrow L = (2 \times 270) + (3 \times 630)$

= 540 + 1890

= 2430

**ដូចនេះ:** សម្ព័ន្ធអ៊ីដ្រូសែនមានចំនួន | 2430 សម្ព័ន្ធអ៊ីដ្រូសែន |

គ. គណនាចំនួនម៉ាសម៉ូលេគុល

<u>បំរាប់</u> ម៉ាសអាស៊ីតអាមីនេមានចំនួន 110 ខ្នាតកាបូន

<u>តាមសម្រាយ</u> m= 900

+រកចំនួនកូដុង

ដោយ នុយក្លេអូទីតបីតគ្នាជាក្រុមអាស៊ីតអាមីនេមួយ

នាំអោយ កូដុង = m÷3

= 900 ÷ 3 =300 កូដុង

+រកអាស៊ីតអាមីនេ

ដោយកូដុងមានពីរ គឺកូដុងផ្តើម និង កូដុងស្តប់

នាំអោយ អាស៊ីតអាមីនេ = កូដុង - 2

= 300 – 2 = 198 អាស៊ីតអាមីនេ

→ ម៉ាសសរុប = អាស៊ីតអាមីនេ × 110

= 198 × 110 = 21780 ខ្នាតកាបូន

**<u>ដូចនេះ</u>** ម៉ាសម៉ូលេគុលប្រូតេអ៊ីនស្មើ 21780 ខ្នាតកាបូន

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**................................. |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥** | **ឈ្មោះបេក្ខជ**..................................... |
| | **ហត្ថលេខាបេក្ខជន**............................. |

## ប្រធាន

I. ចូរពណ៌នាអំពីការបង្កើតកំណើតរបស់រុក្ខជាតិអង់ស្យូស្ពែម?

II. តើអាំងភ្លុចប្រសាទមានទិសដៅពីណាទៅណា?

III. ហេតុអ្វីបានជាសីតុណ្ហភាពខ្ពស់ពេកទាបអង់ស៊ីមប្រែជាបាត់បង់គុណភាព?

IV. ចូរពណ៌នាពីរបៀបផលិតអរម៉ូនអាំងស៊ុយលីនរបស់មនុស្ស?

V. ម៉ូលេគុលADNមួយមាននុយក្លេអូទីត $T_1$=500 និង $G_1$=700?
ADNនេះមានសម្ព័ន្ធអ៊ីដ្រូសែនសរុប5700។ ARN$_m$ដែលចម្លងចេញពីម៉ូលេគុលADNខាងលើមានប្រវែង748nm។

ក. ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗក្នុងច្រវ៉ាក់ទោលនីមួយៗរបស់AND។

ខ. ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ម៉ូលេគុលARN$_m$ដែលចម្លងចេញពីច្រវ៉ាក់ទី1 របស់ADN ។

គ. ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ADN។

VI. ប្រូទីតមួយមានប្រវែង5192A$^0$។ ប្រូទីតនេះសំយោគចេញពីសែនមួយមាននុយក្លេអូទីតប្រភេទកានីន និង ស៊ីតូស៊ីនស្មើ40%នៃចំនួនក្លេអូទីតទាំងអស់។ ដោយដឹងថាអាស៊ីតអាមីណេនីមួយៗមានប្រវែង4A$^0$។

ក/ ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន?

ខ/ គណនាសមាមាត្រភាគនុយក្លេអូទីតប្រភេទនីមួយៗរបស់សែន?

គ/ គណនាចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុបរបស់សែន?

# អត្រាកំណែ

I. ពណ៌នាអំពីការបង្កកំណើតរបស់រុក្ខជាតិអង់ស្យូស្ពែម:

ពេលគ្រាប់លំអងធ្លាក់លើស្ទិចម៉ាតណ្ឌៃយ៉ូលូតលាស់ពន្លូតខ្លួនចាក់ចូលទៅក្នុងថង់អំប្រីយ៉ុង ចំណែកឯណ្ឌៃយ៉ូបន្តពូជចែកខ្លួនបានស្ពែម៉ូតូសូអ៊ីតចំនួនពីរ រួចធ្វើដំណើរតាមបំពង់លំអងចូលក្នុងថង់អំប្រីយ៉ុង ក្នុងពេលតែមួយស្ពែម៉ាតូសូអ៊ីត១រលាយជាមួយអូស្វ៊ែបង្កើតបានជាស៊ីកូត(2n)ចំណែកឯស្ពែម៉ាតូសូអ៊ីតមួយរលាយជាមួយកោសិកា ប៉ូលែ បង្កើតបានជាអាល់ប៊ុយមែន

(3n)។

II. អាំងក្លុចប្រសាទមានទិសដៅពីដង់ឌ្រីតទៅតួកោសិកានិងពីអាក់សូនទៅចុងនៃអាក់សូន។

III. បានជាសីតុណ្ហភាពខ្ពស់ពេកឬទាបពេកអង់ស៊ីមប្រែជាបាត់បង់គុណភាពព្រោះ អង់ស៊ីមជាប្រូតេអ៊ីន។

កាលណាសីតុណ្ហភាពខ្ពស់ពេកឬទាបពេកធ្វើឲ្យសម្ព័ន្ធប៊ិបទីតនឹងសម្ព័ន្ធអ៊ីដ្រូសែននៅក្នុងអង់ស៊ីមត្រូវបានផ្ដាច់ដែលបណ្ដាលឲ្យអង់ស៊ីមផ្លាស់ប្ដូរទម្រង់ នាំឲ្យអង់ស៊ីមមិនអាចបំពេញនាទីជាកក្ដាលិករបាន។

IV. ពណ៌នាពីរបៀបផលិតអម៉ូនអាំងស៊ុយលីនរបស់មនុស្ស:

- កាត់: គេកាត់អង្គត់ADNរបស់មនុស្សដែលជាសែនសំយោគអរម៉ូនអាំងស៊ុយលីននិងកាត់អង្គត់ADNរបស់បាក់តេរីដោយអង់ស៊ីមបង្រួម។
- គេបញ្ចូលអង្គត់ADNរបស់មនុស្សទៅក្នុងប្លាស្មីតរបស់បាក់តេរីដោយអង់ស៊ីមភ្ជាប់ បង្កើតបានADNបន្សំថ្មី
- គេបញ្ចូលADNបន្សំថ្មីទៅក្នុងបាក់តេរី។ បាក់តេរីកើនចំនួននាំឲ្យសែនសំយោគអរម៉ូនអាំងស៊ុយលីនក៏កើនចំនួនដែរ ។
- សែននីមួយសំយោគបានជាអរម៉ូនអាំងស៊ុយលីនសម្រាប់ព្យាបាលជំងឺទឹកនោមផ្អែម។

V. ក/ រកចំនួននុយក្លេអូទីតប្រភេទនីមួយក្នុងច្រវ៉ាក់ទោលនីមួយៗរបស់AND

($A_1$; $T_1$; $C_1$; $G_1$; $A_2$; $T_2$; $C_2$; $G_2$)

<u>បម្រាប់</u> $L=5700$ ; $L_{ARNm}=748nm$ ; $T_1=500$ ; $G_1=700$

តាមគោលការណ៍បំពេញបាស A-T ; C-G

ដោយនុយក្លេអូទីត1មានប្រវែង 0,34nm

តាមរូបមន្ត $L_{ARNm}$= m x 0,34nm => m = $\frac{\text{LARNm}}{0,34nm}$

=> m = $\frac{748}{0,34nm}$ = 2200

ដោយរីបូនុយ1ចម្លងពីច្រវ៉ាក់ម្ខាងរបស់AND

=> M = 2m =2× 2200=4400

ដោយ A-T ដោយសម្ព័ន្ធHចំនួន 2 = 2A

C-G ដោយសម្ព័ន្ធHចំនួន 3 = 3C

តាមរូបមន្ត L= 2A + 3C

⇔5700= 2A + 3C

ដោយADN1មាននុយក្លេអូទីត4ប្រភេទ A,T,C,G

=> M = 2(A+C)

=> 4400 = 2(A+C)

=> $\frac{4400}{2}$ =A+C => A = 2200 - C

ជំនួសចូល

L = 2A + 3C

=> 5700 = 2(2200 - C) + 3A

= 4400 + C => C=1300 ជួរ

=> C= $C_1$+$C_2$ => $C_1$=C-$C_2$

=> $C_1$= (13-7) x $10^2$= 600

=>A = 2200-1300 = 900

=> A = $A_1$+$A_2$ = $A_1$ = A-$A_2$

= (9 -5) x $10^2$ = 400

**ដូចនេះ** $A_1 = T_2 = 400$ ; $T_1 = A_2 = 500$ ; $C_1 = G_2 = 600$ ; $G_1 = C_2 = 700$

ខ/ រកចំនួនរីបូនុយក្លេអូទីតប្រភេទនីមួយៗរបស់ $ARN_m$ ដែលចម្លងចេញពីច្រវ៉ាក់ទី១ របស់AND(A;U;C,G)

AND { U A G C ; $A_1 - T_1 - C_1 - G_1$ ; $T_2 - A_2 - G_2 - C_2$ }

ដោយ $A_{ARNm} = T_1+A_2 =400$

$U_{ARNm} = A_1+T_2 =500$

$C_{ARNm} = G_1+C_2 =700$

$G_{ARNm} = C_1+G_2 =600$

**ដូចនេះ** $A_{ARNm} = 400$ ; $U_{ARNm} = 500$ ; $C_{ARNm} = 700$ ; $G_{ARNm} = 600$

គ/ រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់AND(A,T,C,G)

តាមគោលការណ៍បំពេញបាស A - T ; C - G

$A = A_1 + A_2$

$= (4 + 5) x 10^2= 900$

$C = C_1 + C_2$

$= (7 + 6) x 10^2= 1300$

**ដូចនេះ** A = T = 900 ; C = G = 1300

VI. ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន(A,T,C,G)

តាមគោលការណ៍បំពេញបាសA -T ; C - G

បម្រាប់ $L_{ប្រូទីត} = 192A^0 = 1.92$ nm ; G + C = 40% x M

$L_{aa1} = 4A^0 = 0.4$mm

$=>L_{ប្រូទីត} = L_{aa1}$ x ចំនួន aa => ចំនួន aa = $\frac{L_{ប្រូទីត}}{Laa1}$

=>ចំនួន aa = $\frac{1.92}{0.4}$ = 48

ដោយកូដុងមួយជាក្រមកំណត់$aa_1$លើកលែងកូដុងស្តុប១ពេលសំយោគប្រូតេអ៊ីនចប់មេត្យូនីនផ្តាច់ពីប៉ូលីប៉ិបទីត

តាមរូបមន្ត ចំនួន aa = ចំនួនកូដុង-2 => ចំនួនកូដុង = ចំនួន aa + 2

=>ចំនួនកូដុង = 48 + 2 = 50

ដោយរីបូនុយ៣ត្រូវនឹង1កូដុង

=>ចំនួនកូដុង = m ៖ 3 => m = ចំនួនកូដុង x 3

=> m = 50 x 3 = 150

ដោយរីបូនុយក្លេអូទីត1ចម្លងពីច្រវ៉ាក់ម្ខាងរបស់AND

=> m = M ៖ 2 => M = 2 x m = 2 x 150 = 300

ជំនួសចូលសមីការ(1)

$2C = (40 / 100) \times 3 \times 10^2 = 120 \Rightarrow C = 60$

ដោយសែន១មាននុយក្លេអូទីត៤ប្រភេទគឺ A,T,C,G

=> M = 2(A + C)

<=> 300 / 2 = A + 60 => A = 90

**ដូចនេះ** A = T = 90 ; C = G = 60

ខ. គណនាសមាមាត្រភាគរយនុយក្លេអូទីតប្រភេទនីមួយៗរបស់សែន

(%A ; %T ; %C ; %G)

$\Rightarrow \%A = \frac{100 \times A}{M} = \frac{100 \times 90}{300} = 30\%$

$\Rightarrow \%C = \frac{100 \times C}{M} = \frac{100 \times 60}{300} = 20\%$

**ដូចនេះ** %A=%T= 30% ; %C=%G= 20%

គ. គណនាចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុប

ដោយ A - T ដោយសម្ព័ន្ធHចំនួន 2 = 2A

C - G ដោយសម្ព័ន្ធHចំនួន 3 = 3A

⇨ $L = 2A + 3C$

$= (2 \times 90) + (3 \times 60) = 360$

ដូចនេះ ចំនួនសម្ព័ន្ធអ៊ីដ្រូសែនសរុប = 360 សម្ពន្ធ័អ៊ីដ្រូសែន

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**<br>**សម័យប្រឡង ២១ ធ្នូ ២០២០**<br>**វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)**<br>**រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥** | **សម័យប្រឡង**..................................<br>**មណ្ឌលប្រឡង**..................................<br>**លេខបន្ទប់**..............**លេខតុ**................<br>**ឈ្មោះបេក្ខជ**.......................................<br>**ហត្ថលេខាបេក្ខជន**............................. |

## ប្រធាន

I. តើរុក្ខជាតិអង់ស្យូស្ពែមមានប្រយោជន៍ដូចម្ដេចខ្លះ?ចូររកឧទាហរណ៍ឲ្យបាន3។

II. តើក្រពេញអ៊ីប៉ូភីសមុខផលិតអរម៉ូនអ្វីខ្លះ?

III. តើវិស្វកម្មសេនេទិចមានប្រយោជន៍ដូចម្ដេចខ្លះដល់កសិករ?

IV.ច្រវាក់ម្ខាងរបស់សែនមួយមាន 900នុយក្លេអូទីត។

១,គណនាប្រវែងរបស់សែនគិតជាដេស៊ីម៉ែត្រ?

២,បើម៉ូលេគុល $ARN_m$ មួយដែលចម្លងចេញពីច្រវាក់ម្ខាងរបស់សែនខាងលើមានសមាមាត្ររីបូនុយក្លេអូទីត $\frac{3}{A} = \frac{4}{U} = \frac{5}{C} = \frac{6}{G}$។ ចូររកចំនួនរីបូនុយក្លេអូទីតប្រភេទនីមួយៗរបស់ $ARN_m$?

V.ម៉ូលេគុលADNមួយមានប្រវែង0,34មីក្រូម៉ែត្រហើយមានសម្ព័ន្ធអ៊ីដ្រូសែន2700។

១,ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ADNនេះ?

២,នៅពេលម៉ូលេគុលADNខាងលើស្វ័យតំឡើងទ្វេ 3ដង តើវាត្រូវការនុយក្លេអូទីតសេរីប្រភេទនីមួយៗចំនួនប៉ុន្មាន?

៣,តើម៉ូលេគុលADNនេះមានប៉ុន្មានស្ពៀរ?

# អត្រាកំណែ

I.រុក្ខជាតិអង់ស្យូស្ពែមមានប្រយោជន៍ដូចជា:

- ជាប្រភពអាហារ
- ផ្តល់អុកស៊ីសែនសម្រាប់ដកដង្ហើម
- អាចធ្វើជាសំណង់នឹងគ្រឿងសង្ហារឹមប្រណិត
- អាចធ្វើជាក្រដាស់
- អាចធ្វើជាឱសថ
- អាចធ្វើជាសម្លៀកបំពាក់
- អាចធ្វើជាជ័រ,កៅស៊ូ
- អាចធ្វើជាសម្ភារះផ្សេងៗទៀត។

ឧទាហរណ៍:

- ក្រញូង,បេង,នាងនួន=>អាចធ្វើជាគ្រឿងសង្ហារឹមបាន
- កប្បាស =>អាចធ្វើជាសរសៃអំបោះបាន
- កៅស៊ូ =>អាចធ្វើជាសំបកកង់រថយន្តបាន។

II.ក្រពេញអ៊ីប៉ូភីសមុខផលិតអរម៉ូនដូចជា:

- GH (អ័រម៉ូន លូតលាស់)
- PRL (អ័រម៉ូន ប្រូឡាក់ទីន)
- MSH (អ័រម៉ូន មេឡាណូស៊ីតស្ទីមុយឡង់)
- TSH (អ័រម៉ូន ទីរេអូស្ទីមុយលីន)
- ACTH (អ័រម៉ូន អាដ្រេណូករទីកូត្រូប)
- GSH (អ័រម៉ូន កូណាដូស្ទីមុយលីន) ។

III.វិស្វកម្មសេនេទិចមានប្រយោជន៍ដល់កសិករដូចជា:

- ផលិតអ័រម៉ូនលូតលាស់
- កែច្នៃពូជរុក្ខជាតិឲ្យលូតលាស់ឆាប់រហ័សផ្តល់ទិន្នផលខ្ពស់ធន់នឹងជំងឺ អាកាសធាតុ ថ្នាំសម្លាប់សត្វល្អិតហើយនឹងជួយបង្កើនគុណភាពដីដាំដំណាំ។

IV.1,គណនាប្រវែងរបស់សែនគិតជាដេស៊ីម៉ែត្រ(l)

<u>បម្រាប់</u> $\frac{M}{2}$ = 900 =>M = 1800

ដោយនុយក្លេអូទីតមួយមានប្រវែង 0,34nm

➩ $l_{សែន} = \frac{M}{2} \times 0,34nm$

$= 900 \times 0,34 = 306 \times 10^{-8}$dm

**ដូចនេះ** $l_{សែន} = 306 \times 10^{-8}$dm

2, រកចំនួនរីបូនុយក្លេអូទីតប្រភេទនីមួយៗរបស់ $ARN_m$ (A,U,C,G)

តាមគោលការ ចម្លងក្រុម A - U តែ $A \neq U$ ; C - G តែ $C \neq G$

<u>បម្រាប់</u> $\frac{3}{A}$ARNm = $\frac{4}{U}$ARNm = $\frac{5}{C}$ARNm = $\frac{6}{G}$ARNm

<=> $\frac{3}{A}$ARNm = $\frac{4}{U}$ARNm => $U_{ARNm} = \frac{(4A)\ ARNm}{3}$

<=> $\frac{3}{A}$ARNm= $\frac{5}{C}$ARNm => $C_{ARNm} = \frac{(5A)ARNm}{3}$

<=> $\frac{3}{A}$ARNm=$\frac{6}{G}$ARNm => $G_{ARNm} = \frac{(6A)ARNm}{3}$

ដោយ ARNmមួយនុយក្លេអូទីត 4 ប្រភេទគឺ A,U,C,G

➩ $m = A_{ARNm} + U_{ARNm} + C_{ARNm} + G_{ARNm}$

ដោយរីបូនុយមួយចម្លងចេញពីច្រវ៉ាក់ម្ខាងរបស់AND

➩ m = 900

<=> $9000 = A_{ARNm} + \frac{(4A)ARNm}{3} + \frac{(5A)ARNm}{3} + \frac{(6A)ARNm}{3}$

$= A_{ARNm} + \frac{(15A)ARNm}{3}$

<=> 2700 = 18AARNm => $A_{ARNm} = 1500$

=> $U_{ARNm} = 4 \times \frac{1500}{3} = 2000$

=> $C_{ARNm} = 5 \times \frac{1500}{3} = 2500$

=> $G_{ARNm} = 6 \times \frac{1500}{3} = 3000$

**ដូចនេះ** $A_{ARNm} = 1500$ ; $U_{ARNm} = 2000$ ; $C_{ARNm} = 2500$; $G_{ARNm} = 3000$

V.1. រកចំនួននុយក្លេអូទីតប្រភេទប្រភេទនីមួយៗរបស់AND(A,T,C,G)

តាមគោលការណ៍ បំពេញបាស A = T,C = G

<u>បម្រាប់</u> $L_{សែន}$ = 0,34um = 340nm , L = 2700

ដោយនុយក្លេអូទីតមួយមានប្រវែង0,34nm

=> $L_{ADN} = \frac{M}{2} \times 0,34$nm => $M = 2 \times \frac{l\ ADN}{0,34}$

=> $M = 2 \times \frac{340}{0,34} = 2000$

ដោយ ADN មួយមាននុយក្លេអូទីត 4 ប្រភេទគឺ A,T,C,G

➩ M = 2(A+C)

<=> 2000= 2 (A+C)

<=> 1000= A+C => A = 1000-C

ដោយ A - T ដោយសម្ព័ន្ធ H ចំនួន 2

C – G ដោយសម្ព័ន្ធ H ចំនួន 3

⇨ L = 2A + 3C

<=> 2700 = 2 (1000-C) + 3C

<=> 2700 - 200 = C

=> C = 700

=> A= 1000 – 700 = 300

**ដូចនេះ:** A=T= 300 ;C=G= 700

2. រកចំនួននុយក្លេអូទីតសេរីប្រភេទនីមួយៗរបស់AND ;

បម្រាប់ n = 3

ដោយADNមេមួយស្វ័យដំឡើងទ្វេ 1 ដងបានADNកូន $2^1$

2 ដងបានADNកូន $2^2$

3 ដងបានADNកូន $2^3$

↓ ↓

n ដងបានADNកូន $2^n$

A’ = A ( $2^n$-1)

= 300( $2^3$-1) = 2100

C’= C( $2^n$-1)

= 700( $2^3$-1) = 4900

**ដូចនេះ:** A’=T’= 2100 , C’=G’= 4900

3. រកចំនួនស្ពៀររបស់ម៉ូលេគុលADN

ដោយស្ពៀរស្មើ 10 គូស្មើនឹងនុយក្លេអូទីតចំនួន២០

=>ចំនួនស្ពៀរ = $\frac{M}{20} = \frac{2000}{20}$ = 100

ដូចនេះ: ចំនួនស្ពៀរ = 100

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**................................ |
| **សម័យប្រឡង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**.............................. |
| **វិញ្ញាសា៖ ជីវវិទ្យា ( ថ្នាក់វិទ្យាសាស្ត្រ )** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥** | **ឈ្មោះបេក្ខជ**.................................. |
| | **ហត្ថលេខាបេក្ខជន**........................... |

## ប្រធាន

I. ចូរពណ៌នាផ្នែកផ្សេងៗនៃណឺរ៉ូន។

II. ចូរបកស្រាយគំរូម៉ូលេគុលADNរបស់លោកគ្រិកនឹងលោកវ៉ាត់ស៊ុន។

III. តើអង់ស៊ីមមានសកម្មភាពប្រសើរបំផុតនៅសីតុណ្ហភាពប៉ុន្មាន? នៅកម្រិតpH ស្មើប៉ុន្មាន?

IV. តើប៉ូលីប្លូអ៊ីឌីផ្តល់ផលប៉ះពាល់ដូចម្តេចចំពោះសត្វ?

V. ការបង្កាត់ឆ្ងាយផ្តល់ផលអាក្រក់ដូចម្តេច?

VI. ចូរពណ៌នាការពិសោធន៍របស់លោកអាវើរី។

VII. នៅពេលធ្មួលក្លិនត្រូវបានភ្លោចតើមានអ្វីកើតឡើង?

VIII. ម៉ូលេគុល $ARN_m$ មួយមានរីបូនុយក្លេអូទីតA= 480 ហើយមានផលដកCនឹងGស្មើចំនួនរីបូនុយU។សែនដែលកំណត់សំយោគ $ARN_m$នេះមានផលធៀបA $= \frac{3}{2} \times$ Cនិងនៅលើច្រវ៉ាក់ទី1 មាន$G_1$= 30%នៃចំនួននុយក្លេអូទីតច្រវ៉ាក់ម្ខាង។

1. គណនាចំនួនសម្ព័ន្ធគីមីក្នុងសែនដែលកំណត់សំយោគ$ARN_m$នេះ
2. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន
3. គណនាចំនួនសម្ព័ន្ធបិបទីតក្នុងម៉ូលេគុលប្រូតេអ៊ីន។

IX. សែនមួយមានសម្ព័ន្ធកូវ៉ាឡង់ចំសែន2798 ។ម៉ូលេគុល$ARNm_1$ដែលសំយោគចេញពីសែនខាងលើមានរីបូនុយក្លេអូទីត $\frac{A}{C} = \frac{1}{2}$; U+C= 700 ; G-U= 200។

1. ចូររកចំនួននុយក្លេអូទីតប្រភេទនៅមួយៗរបស់ម៉ូលេគុល ARNm
2. ចូររកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន។

# អត្រាកំណែ

I. ពណ៌នាផ្នែកផ្សេងៗនៃណឺរ៉ូនមាន៣សំខាន់ៗគឺ:

- ដង់ឌ្រីត : ជាសរសៃឆ្មារៗខ្លីដែលបែកចេញពីតួកោសិកា។មាននាទីដឹកនាំអាំងភ្លុចប្រសាទហើយបញ្ជូនព័ត៌មានទៅកាន់កោសិកា។
- តួកោសិកា : ជាផ្នែកធំជាងគេនៃណឺរ៉ូនដែលផ្ទុកជាតុកោសិកាដូចជា មីតូកុងឌ្រីប្រដាប់កុលស៊ីរេទីគុយឡូមអង់ដូប្លាសសារជាតុនីលនិងណឺរ៉ូនគីប្រើជាដើម។មាននាទីបញ្ជូនព័ត៌មានអាក់សូន។
- អាក់សូន : ជាពន្លយដែលបែកចេញតួកោសិកាតែមួយវែងហើយធំ។

II. បកស្រាយគំរូម៉ូលេគុលADNរបស់លោកគ្រិកនិងលោកវ៉ាត់ស៊ុន:

- ម៉ូលេគុលADNកើតពីច្រវ៉ាក់នុយក្លេអូទីត២ខ្សែរុំជារង្វេលដែលស្មើនឹងស្របគ្នាហើយមានទទឹង២nm ហើយបណ្តាលពីច្រើនmm->ច្រើនម៉ែត្រ។
- ក្នុងច្រវ៉ាក់ម្ខាងនុយក្លេអូទីតនីមួយៗភ្ជាប់គ្នាដោយសម្ព័ន្ធគីមីត្រង់$C_5H_{10}O_4$នៃចំនន្ទនុយក្លេអូទីតមួយទៀត។
- ច្រវ៉ាក់ទាំង២របស់ADNភ្ជាប់គ្នាដោយសម្ព័ន្ធអ៊ីដ្រូសែនចងបាសA&Tដោយសម្ព័ន្ធអ៊ីដ្រូសែនចំនន្ទ២ហើយត្រង់បាសC&Gដោយសម្ព័ន្ធអ៊ីដ្រូសែនចំនន្ទ៣។

III. អង់ស៊ីមមានសកម្មភាពប្រសើរបំផុតនៅសីតុណ្ហភាពពី$40C^0$ដល់$45C^0$។

- នៅកម្រិតpH= 7 ។

IV. ប៉ូលីប្លូអ៊ីឌីផ្តល់ផលប៉ះពាល់ចំពោះសត្វគឺបណ្តាលឲ្យសត្វស្លាប់។

V. ការបង្កាត់ឆ្ងាយផ្តល់ផលអាក្រក់គឺអ៊ីប្រីតអារ ករណីមេបាប្រភេទខុសគ្នា។

VI. ពណ៌នាការពិសោធន៍របស់លោកអាវ៉ឺ ៖

គាត់យកប្រូតេអ៊ីន Sស្លាប់លាយជាមួយRបានបន្ទាប់មកគាត់ចាក់ល្បាយនេះទៅក្នុងខ្លួនកណ្តុរឃើញថាកណ្តុរស្លាប់។

VII. នៅពេលធ្លួលក្លិនត្រូវបានភ្ញោចគឺពេលដកដង្ហើមចូលម៉ូលេគុលក្លិនរលាយក្នុងភ្នាសស្លេស្មទៅជាល្បាយ

បន្ទាប់មកល្បាយនេះភ្ញោចធ្លួលក្លិនអាំងភ្លុចប្រសាទបានកើតឡើងរួចធ្វើដំណើរតាមសរសៃប្រសាទឃានវិញ្ញាណទៅកាន់ខួរក្បាល។ខួរក្បាលបកប្រែទៅជាក្លិនខុសៗគ្នា។

VIII. 1. គណនាចំនួនសម្ព័ន្ធគីមីក្នុងសែន

<u>បម្រាប់</u> $ARN_m = 480$ ; $C_{ARNm} - G_{ARNm} = U_{ARNm}$ ; $A = \frac{3}{2}\times C$ ; $G_1 = 30\% \times \frac{M}{2}$

ដោយ$ARN_m$ចម្លងពីច្រវ៉ាក់ម្ខាងរបស់សែន

⇨ $G_1 = C_{ARNm}$

<=> $G_1 = \frac{30}{100} \times m$

<=> $C_{ARNm} = \frac{3}{10}(A_{ARNm} + U_{ARNm} + C_{ARNm} + G_{ARNm})$

<=> $10C_{ARNm} = 3(480 + C_{ARNm} - G_{ARNm} + C_{ARNm} + G_{ARNm})$

<=> $10C_{ARNm} = 1440 + 6C_{ARNm}$

<=> $4C_{ARNm} = 1440$

⇨ $C_{ARNm} = 360$

<=> $G_{ARNm} = 360$

<=> $360 = \frac{30}{100} \times \frac{M}{2}$

<=> $360 = \frac{3M}{2}$ => $M = \frac{7200}{3} = 2400$

ដោយក្នុងច្រវ៉ាក់ម្ខាងនុយក្លេអូទីតនីមួយៗភ្ជាប់គ្នាដោយសម្ព័ន្ធគីមីហើយសែនមួយមានច្រវ៉ាក់នុយក្លេអូទីត២ខ្សែ

⇨ ចំនួនសម្ព័ន្ធគីមីសរុប = M - 2

= 2400 – 2 = 2398

**<u>ដូចនេះ</u>** ចំនួនសម្ព័ន្ធគីមីសរុប = 2398

2. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន(A,T,C,G)

តាមគោលការណ៍បំពេញបាស A - T , C - G

ដោយសែនមួយមាននុយក្លេអូទីត 4ប្រភេទគឺ A,T,C,G

⇨ M = 2(A+C)

<=> 1200 = A+C

⇨ A = 1200 - C

<=> $1200 = \frac{3}{2} \times C$

<=> 2400 - 2C = 3C

=> C = 480

=> A = 1200 – 480 = 720

**<u>ដូចនេះ</u>** A = T = 720 , C = G = 480

3. គណនាចំនួនសម្ព័ន្ធប៉ិបទីតក្នុងម៉ូលេគុលប្រូតេអ៊ីន

ដោយ$ARN_m$មួយចម្លងពីច្រវ៉ាក់ម្ខាងរបស់សែន

=> $M = \frac{m}{2} = 1200$

ដោយរីបូនុយ 3 ត្រូវនឹង 1 កូដុង

=>ចំនួន= $\frac{M}{3} = \frac{1200}{3} = 400$

ដោយកូដុងមួយជាក្រមកំណត់aa 1លើកលែងកូដុងស្តុប1ពេលសំយោគប្រូតេអ៊ីនចប់មេត្យូនីនផ្តាច់ពី

ប៉ូលីប៉ិបទីត

⇨ ចំនួនaa = ចំនួនកូដុង-2

<=> ចំនួនaa = 400 – 2 = 398

ដោយaa នីមួយៗភ្ជាប់គ្នាដោយចំណងប៉ិបទីត

=>ចំនួនសម្ព័ន្ធប៉ិបទីត=ចំនួនaa - 1

= 398 – 1 = 397

**ដូចនេះ** ចំនួនសម្ព័ន្ធប៉ិបទីត = 397

IX. 1. រកចំនួនរីបូនុយប្រភេទនីមួយៗរបស់$ARN_m$ (A,U,C,G)

តាមគោលការណ៍ចម្លងក្រម A-U , C-G

បម្រាប់ ចំនួនសម្ព័ន្ធគីមីសរុប = 2798

$ARN_m / C_{ARNm} = \frac{1}{2} \Leftrightarrow A_{ARNm} = \frac{(C\ )ARNm}{2}$

⇨ $C_{ARNm} = 2A_{ARNm}$

$U_{ARNm} + C_{ARNm} = 700$ ; $G_{ARNm} - U_{ARNm} = 200$

=> $U_{ARNm} = 700 - 2A_{ARNm}$

=> $G_{ARNm} = 900 - 2A_{ARNm}$

ដោយក្នុងច្រវ៉ាក់ម្ខាងៗនុយក្លេអូទីតនីមួយៗភ្ជាប់ដោយសម្ព័ន្ធគីមីហើយADNមួយមានច្រវ៉ាក់នុយក្លេអូទីត2ខ្សែ

=>ចំនួនសម្ព័ន្ធគីមីសរុប=M-2

=> M = 2798 + 2 = 2800

ដោយរីបូនុយក្លអូទីតមួយចម្លងចេញពីច្រវ៉ាក់ម្ខាងរបស់ADN

⇨ $m = \frac{M}{2} = \frac{2800}{2} = 1400$

ដោយរីបូនុយមួយមាននុយក្លេអូទីត 4 ប្រភេទគឺ A,U,C,G

⇨ $m = A_{ARNm} + U_{ARNm} + C_{ARNm} + G_{ARNm}$

<=> $1400 = A_{ARNm} + (700 - 2A_{ARNm}) + 2A_{ARNm} + (900 - 2A_{ARNm})$

$= A_{ARNm} + 1600$

<=> $A_{ARNm} = 200$

=> $U_{ARNm} = 700 - (2 \times 200) = 300$

=> $C_{ARNm} = 2 \times 200 = 400$

=> $G_{ARNm} = 900 - (2 \times 200) = 500$

**ដូចនេះ:** $A_{ARNm} = 200$ ; $U_{ARNm} = 300$ ; $C_{ARNm} = 400$; $G_{ARNm} = 500$

2. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់( A,T,C,G )
តាមគោលការណ៍បំពេញបាស A=T,C=G
ដោយសែនមួយមាននុយក្លេអូទីត4ប្រភេទគឺA,T,C,G

⇨ $M = 2(A+C)$

<=> $1400 = A+C$

⇨ $A_{សែន} = A_{ARNm} + U_{ARNm}$

$= 200 + 300 = 500$

⇨ $C_{សែន} = C_{ARNm} + G_{ARNm}$

$= 400 + 500 = 900$

**ដូចនេះ:** $A_{សែន} = T_{សែន} = 500$; $C_{សែន} = G_{សែន} = 900$

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**................................ |
| **សម័យប្រលង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**................................ |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥** | **ឈ្មោះបេក្ខជ**.................................... |
| | **ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. ដូចម្តេចដែលហៅថាក្រពេញទីរ៉ូអ៊ីត? វាមាននាទីដូចម្តេច?

II. តើហេតុអ្វីបានជាគេថាគ្រាប់លម្អងមិនមែនជាកាម៉េតឈ្មោល? ចូរពន្យល់ ។

III. ១. ចូរសរសេររូបមន្តទូទៅរបស់អាស៊ីតអាមីនេ ។

២. រ៉ាដីកាល់របស់អាស៊ីតអាមីនេនៃប្រភេទអាឡានី $-CH_3$ ។
៣. រ៉ាឌីកាល់ $R$ របស់អាស៊ីតអាមីនេនៃប្រភេទសេរីន $-CH_2OH$ ។

IV. ហេតុអ្វីបានជាគេចាត់ទុក ក្រពះនិងពោះវៀនតូចជាក្រពេញអង់ដូគ្រីន?

V. តើចលនាការស្វ័យតម្លើងទ្វេ $ADN$ មានសារៈសំខាន់ដូចម្តេចខ្លះ?

VI. ហេតុអ្វីបានជាគេនិយាយថាអង់ស៊ីមជាប្រូតេអ៊ីនដែលមានសកម្មខ្លាំងក្លា?

VII. ម៉ូលេគុល $ADN$ មួយមានសម្ព័ន្ធអ៊ីដ្រូសែនសរុប $16\times10^4$ ។ នុយក្លេអូទីតប្រភេទ $C$ ច្រើនជាងនុយក្លេអូទីតប្រភេទ $A$ ចំនួនពីរដង។

ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ ADN
ខ. ពេលម៉ូលេគុល ADN ស្វ័យតម្លើងទ្វេ3 ដង តើត្រូវការនុយក្លអូទីតសេរីនីមួយៗចំនួនប៉ុន្មាន?

VIII. ម៉ូលេគុល $ARN_m$ មួយមានទំនាក់ទំនងរវាងបួននុយក្លេអូទីត $A = 4U$ , $\frac{G}{C} = \frac{1}{2}$ , $\frac{U}{G} = \frac{1}{5}$

គណនាភាគរយនុយក្លេអូទីតប្រភេទនីមួយៗរបស់អង្កត់ $ADN$ ដែលកំណត់សំយោគ $ARNm$ នេះ។

# អត្រាកំណែ

I. ក្រពេញប៉ារ៉ាទីរ៉ូអ៊ីតជាក្រពេញរាងពងក្រពើតូចៗចំនួន៤ ដែលកបង្កប់ក្នុងផ្នែកខាងក្រោយនៃក្រពេញទីរ៉ូអ៊ីត។ វាមាននាទីបញ្ចេញឬផលិតអរម៉ូនប៉ារ៉ាទីរ៉ូអ៊ីត(PHT)។

II. បានជាគេថាគ្រាប់លម្អងមិនមែនជាកាម៉េតឈ្មោលព្រោះដោយសារតែះ

- គ្រាប់លម្អងជាកោសិកាមានណ្វៃយ៉ូអាប្លូអ៊ីតពីរ ពោលគឺណ្វៃយ៉ូបន្តពូជ និងណ្វៃយ៉ូបន្តលូតលាស់។
- ណ្វៃយ៉ូលូតលាស់ហាក់បីដូចជានាំដំណើរការលូតលាស់នៃបំពងលម្អង។
- ណ្វៃយ៉ូបន្តពូជចែកតាមមីតូស១ដង បង្កើតជាស្ពែម៉ាតូសូអ៊ីតពីរ គ្មានផ្លាសែល។

ដូច្នេះ សរុបមកយើងឃើញថាគ្រាប់លម្អងមិនមែនជាកាម៉េតឈ្មោលទេ។

III. ១. រូបមន្តទូទៅអាស៊ីតអាមីនេ

$$NH_2 - \underset{\substack{| \\ R}}{CH} - COOH$$

២.អាស៊ីតអាមីនេអាឡានីន

$$NH_2 - \underset{\substack{| \\ CH_3}}{CH} - COOH$$

អាស៊ីតអាមីនេសេរីន

$$NH_2 - \underset{\substack{| \\ CH_2OH}}{CH} - COOH$$

៣. ឌីប៉ិបទីត

$$NH_2 - \underset{\substack{| \\ CH_3}}{CH} - CO - NH - \underset{\substack{| \\ CH_3}}{CH} - COOH$$

IV. ក្រពះនិងពោះវៀនតូចជាក្រពេញអង់ដូគ្រីនព្រោះវាជាក្រពេញដែលផលិតអរម៉ូនហើយបញ្ចេញទៅក្នុងចរន្តឈាមដោយផ្ទាល់

- ក្រពះផលិតអរម៉ូនកាស្ទ្រីន
- ពោះវៀនតូចផលិតអរម៉ូនសេក្រេទីន។

V. ចលនការស្វ័យតម្លើងទ្វេ ADN វាមានសារៈសំខាន់ដែលមានដូចជាះ

- រក្សាចំនួនក្រូម៉ូសូមឲ្យនៅដដែលពេលកោសិកាចែក។
- នៅចំណែកមេតូស កោសិកាមេនិងកោសិកាកូនមាន AND ដូចគ្នា។
- រ៉ាប់រងចំនួន និងរូបរាងក្រូម៉ូសូមឲ្យនៅដដែលក្រោយចំណែកកោសិកា។
- រ៉ាប់រង និងតំហែរក្សាពត៌មានសេនេទិចឲ្យនៅថេរដោយឆ្លងកាត់ជំនាន់។

VI. អង់ស៊ីមជាប្រូតេអ៊ីនមានសកម្មភាពខ្លាំងក្លា ព្រោះអង់ស៊ីមជាប្រូតេអ៊ីនមួយចំនួនតូចអាចបង្កើតប្រតិកម្មបានចំនួនធំ។

VII. ក. រកចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ ADN

តាមបម្រាប់ L = 160000 , C = 2A

ដោយ $A$ ភ្ជាប់$T$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 2

$C$ ភ្ជាប់$G$ ដោយសម្ព័ន្ធអ៊ីដ្រូសែន 3

នាំឲ្យ L= 2A + 3C

$= 2A + 3(2A) = 160000$

$= 8A = 160000$

នាំឲ្យ $A = 20000$

$C = 2A = 40000$

តាមគោលការណ៍បំពេញបាស $A - T$ , $C - G$ នាំឲ្យ $A = T$, $C = G$

**<u>ដូចនេះ</u>** ចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ADN

| |
|---|
| $A = T = 20000$ នុយក្លេអូទីត |
| $C = G = 40000$ នុយក្លេអូទីត |

ខ. គណនាចំនួននុយក្លេអូទីតសេរីនីមួយៗ

$ADN$ មេ1 ស្វ័យតម្លើងទ្វេ 1ដងទទួលបាន $ADN$ កូន $2^1$

2ដងទទួលបាន$ADN$ កូន $2^2$

3 ដងទទួលបាន $ADN$ កូន $2^3$

……………………………………………

$n$ ដងទទួលបាន $ADN$ កូន $2^n$

ដោយ$ADN$ មេមួយស្វ័យតម្លើងទ្វេ 3 ដងទទួលបាន $ADN$ កូន $2^3$ ក្នុងនោះមាន $ADN$ មេ1 និង $ADN$ កូនថ្មី$2^3$-1

$A' = T' = A(2^3 - 1) = 20\,000(2^3 - 1) = 140\,000$ នុយក្លេអុទីត

$C = G' = C(2^3 - 1) = 40\,000 \times 7 = 280\,000$ នុយក្លេអូទីត

<u>ដូចនេះ</u> ចំនួននុយក្លេអូទីតសេរីប្រភេទនីមួយៗរបស់$ADN$ គឺ

| |
|---|
| $A' = T' = 140\,000$ នុយក្លេអូទីតសេរី |
| $C' = G' = 280\,000$ នុយក្លេអូទីតសេរី |

VIII. គណនាសមាមាត្រជាភាគរយនៃនុយក្លេអូទីតនីមួយៗរបស់អង្គត់ADN

បម្រាប់ $ARN_m$ មាន

$$A = 4U \,,\ \frac{G}{C} = \frac{1}{2} \,,\ \frac{U}{G} = \frac{1}{5}$$

$$\Rightarrow G = 5U$$

$$C = 2G = 2 \times 5U = 10U$$

$ARNm$ ជាប្រវ៉ាក់ទោល

$$A + U + C + G = 100\%$$

$$4U + U + 10U + 5U = 20U$$

$$20U = 100\%$$

$$\Rightarrow U = \frac{50}{20} = 5\%$$

$$A = 4 \times 5\% = 20\%$$

$$G = 5 \times 5\% = 25\%$$

$$C = 10 \times 5\% = 50\%$$

តាមគោលការណ៍ចម្លងក្រម

$$\%A = \%T = \frac{(A + U)_{ARNm}}{2} = \frac{20 + 5}{2} = 12.5\%$$

$$\%C = \%G = \frac{(C + G)_{ARNm}}{2} = \frac{50\% + 25\%}{2} = 37.5\%$$

**<u>ដូចនេះ</u>**

| |
|---|
| $\%A = \%T = 12.5\%$ |
| $\%C = \%G = 37.5\%$ |

| | |
|---|---|
| **ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | **សម័យប្រឡង**.................................. |
| **សម័យប្រឡង ២១ ធ្នូ ២០២០** | **មណ្ឌលប្រឡង**................................. |
| **វិញ្ញាសា៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** | **លេខបន្ទប់**..............**លេខតុ**................ |
| **រយៈពេល៖ ៩០នាទី ពិន្ទុ ៧៥** | **ឈ្មោះបេក្ខជ**..................................... |
| | **ហត្ថលេខាបេក្ខជន**............................ |

## ប្រធាន

I. តើប្រព័ន្ធប្រសាទមនុស្សមាននាទីអ្វីខ្លះ?

II. ហេតុដូចម្តេចបានជាគេថាស្វ័យតម្លើងទ្វេរ $ADN$ ប្រព្រិត្តិទៅតាមបែបពាក់កណ្តាលរក្សាទុក?

III. ក.ចូរឲឧទាហរណ៍រុក្ខជាតិម៉ូណូកូទីលេដូនឲបាន3 ។

ខ. តើគេសម្គាល់រុក្ខជាតិម៉ូណូកូទីលេដូនបានដោយសារអ្វី?

IV. ដូចម្តេចដែលហៅថាអាំងភ្លុចប្រសាទ?តើអាំងភ្លុចប្រសាទឆ្លងកាត់ស៊ីណាប់យ៉ាងដូចម្តេច?

V. តើរលកសូរមានឥទ្ធិពលទៅលើផ្នែកផ្សេងៗនៃត្រចៀកយ៉ាងដូចម្តេច?

VI. តើវិស្វកម្មសេនេទិចផ្តល់ផលល្អនិងផលអាក្រក់អ្វីខ្លះដល់មនុស្ស?

VII. ម៉ូលេគុល $ADN$ មួយមាននុយក្លេអូទីតប្រភេទ $C = 35\%$ នៃនុយក្លេអូទីតសរុប ហើយនុយក្លអូទីតប្រភេទ Cលើសនុយក្លេអូទីតប្រភេទ $A$ ចំនួន 4400 ។

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់

ខ. តើម៉ូលេគុល$ADN$ នេះមានប៉ុន្មានជំហាន?

VIII. ម៉ូលេគុល$ARNm$ មួយមានរីបូនុយក្លេអុទីតប្រភេទ$U, A, C, G$ ដោយមានសមាមាត្រចែកតាមលំដាប់ចែកដូចតទៅ $3:4:6:7$ ម៉ូលេគុល$ARNm$ នេះសំយោគចេញពីសែនមួយដែលមានប្រវែង $0.408\mu m$ ។

ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់សែន

ខ. គណនាម៉ាសម៉ូលេគុលនុយក្លេអូទីតនីមួយៗរបស់សែន ។ បើដឹងថានុយក្លេអូទីតមួយមានម៉ាស 300 ខ្នាតកាបូន។

គ. រកចំនួនវង្វេលជុំរបស់សែន ?

# អត្រារកំណែ

I. ប្រព័ន្ធប្រសាទមនុស្សមាននាទី

- ទទួលព័ត៌មាន : យើងអាចដឹងថាមានអ្វីកើតឡើងនៅជុំវិញខ្លួនយើងដោយសារប្រព័ន្ធប្រសាទ
- ការឆ្លើយតបនិងព័ត៌មាន: មជ្ឈមណ្ឌលប្រសាទកំណត់នូវប្រតិកម្មតបទៅនិងព័ត៌មាន
- តំហែរក្សាថេរលំនឹង : ប្រព័ន្ធប្រសាទជួយថែរក្សាថេរលំនឹងដោយបញ្ជាឲ្យសារពាង្គកាយឆ្លើយតបឲ្យបានសមស្របទៅនិងព័ត៌មានដែលទទួលបាន

ឧទាហរណ៍ ពេលធ្វើកីឡាត្រូវដកដង្ហើមញាប់ ពេលឃ្លានត្រូវបរិភោគ។

II. ស្វ័យតម្លើងទ្វេរ ADN ប្រព្រិត្តិទៅតាមពាក់កណ្តាលរក្សាទុក និងពីព្រោះក្នុងចំណោមច្រវ៉ាក់ទាំងពីរនៃម៉ូលេគុល ADNកូនមានច្រវ៉ាក់នុយក្លេអូទីតម្ខាងជាម៉ូលេគុលរបស់ADN មេនិងច្រវ៉ាក់ម្ខាងទៀតកើតថ្មី។

III. ក. ឧទាហរណ៍រុក្ខជាតិម៉ូណូកូទីលេដូន

ខ .គេសម្គាល់រុក្ខជាតិម៉ូណូកូទីលេដូន ដោយសារ

- គ្រាប់របស់វាមានកូទីលេដុង1
- ស្លឹករបស់វាមានទ្រនុងស្រប
- វាមានឫសស្នៃ
- ផ្កាមាន៣ស្រទាប់ឬគុណនិង៣
- បាច់សរសៃនាំស្ថិតនៅរាយប៉ាយ។

IV. អាំងភ្លុចប្រសាទជាពត៌មានដែលណឺរ៉ូនដឹកនាំ។ ឬអាំងភ្លុចប្រសាទជាពត៌មានដែលដឹកនាំតាមបណ្តោយណឺរ៉ូននៅចុងអាក់សូនមានថង់តូចៗជាច្រើនដែលផ្ទុកសារជាតុគីមី( ណឺរ៉ូនបញ្ជូនសារ ) ។ ពេលដែលអាំងភ្លុចប្រសាទទៅដល់ចុងអាក់សូន ថង់ទាំងនោះក៏ផ្ទុះបែក ហើយបញ្ចេញណឺរ៉ូនបញ្ជូនសារឆ្លងកាត់ស៊ីណាប់។ បន្ទាប់មកណឺរ៉ូនបញ្ជូនសារនេះបង្កើតបានអាំងភ្លុចប្រសាទនៅក្នុងដង់ឌ្រីតរបស់ណឺរ៉ូនបន្ទាប់ រួចវាធ្វើដំណើរតាមតួកោសិកា និងចុះក្រោមតាមអាក់សូនរហូតដល់ចុងអាក់សូន។ ថង់តូចៗក៏ផ្ទុះបែកបញ្ចេញសារជាតុគីមី( ណឺរ៉ូនបញ្ជូនសារ )ទៅកាន់ស៊ីណាប់។ សារជាតុគីមីនេះត្រូវបានភ្ញោចកើតបានជាអាំងភ្លុចប្រសាទថ្មីៗនៅក្នុងដង់ឌ្រីតហើយបញ្ជូនទៅក្នុងកោសិកាចុះតាមអាក់សូន។

V. រលកសូរមានឥទ្ធិពលទៅលើផ្នែកផ្សេងៗរបស់ត្រចៀក៖

- ត្រចៀកក្រៅ: ស្លឹកត្រចៀកប្រមូលផ្តុំរលកសូរហើយ រន្ធត្រចៀក( បំពង់សោតវិញ្ញាណ ) ដឹកនាំរលកសូរទៅកាន់ត្រចៀកកណ្តាលដោយឆ្លងកាត់ក្រដាសត្រចៀក។ ក្រដាសត្រចៀកញ័រ ហើយលំញ័រត្រូវបានឆ្លងកាត់ត្រចៀកតាមឆ្អឹងតូចៗបី។ ឆ្អឹងទាំងបី ញ័របណ្តាលឲ្យភ្នាសបង្អួចរាងពងក្រពើញ័រ។ លំញ័រនៃភ្នាសនេះធ្វើឲ្យជាតុរាវក្នុងបំពងរាង

គូទខ្សែញ៉ូរ ដែលបណ្តាលឲ្យរោមល្អិតៗនៃកោសិកាផ្ចលក្នុងបំពង់ញ៉ូរនោះ។ ក្រោយមកកោសិកាផ្ចលប្តូរលំញ៉ូរទៅជាអាំងភ្លុចប្រសាទ។

VI. វិស្វកម្មសេនេទិចផ្តល់ផលល្អនិងផលអាក្រក់ដល់មនុស្ស៖

\+ ផលល្អដល់មនុស្ស

- ក្នុងវិស័យសុខាភិបាលៈ ផលិតអាំងស៊ុយលីន អាំងទែឡឺគីន អង់ទីប្យូទិច អង់ទីគ័រ វ៉ាក់សាំង។
- ក្នុងវិស័យកសិកម្មៈ ធ្វើឲ្យរុក្ខជាតិមានផ្កាផ្លែ ធន់និងជម្ងឺ ធន់និងអាកាសធាតុ ធន់និងថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងជួយបង្កើនគុណភាពដីដំណាំ។
- ក្នុងវិស័យឧស្សាហកម្មៈ ស្បៀងផលិតអាហារ មានអរម៉ូន ទឹកដោះគោជូរ ប្រូម៉ាស ស្រាបៀរ នំប៉័ង

\+ ផលអាក្រក់ដល់មនុស្ស

- គ្រោះថ្នាក់ប៉ះពាល់ដល់បរិស្ថាន រុក្ខជាតិ $(GM)$ ធ្វើឲ្យបាត់បង់ជីវិត ជីវៈចម្រុះ សត្វល្អិតធន់និងរុក្ខជាតិ $(GM)$ មានសកម្មភាពពុលដូចជារុក្ខជាតិ$(GM)$ធ្វើឲ្យរុក្ខជាតិអារ មិនអាចផលិតគ្រាប់លម្អងសម្រាប់បន្តពូជ។
- គ្រោះថ្នាក់ប៉ះពាល់ដល់សីលធម៌និងសង្គមៈ ធ្វើឲ្យសៃនមុយតាស្យុងដែលមានឥទ្ធិពលអាក្រក់ដល់សណ្តានក្រោយ ប៉ះពាល់ដល់សាសនា បែងចែកវណ្ណៈ(មានតែអ្នកមានទេទើបអាចធ្វើវិស្វកម្មសេនេទិចនេះបាន)។
- គ្រោះថ្នាក់ប៉ះពាល់ដល់សេដ្ឋកិច្ចៈ ក្រុមហ៊ុនផលិតគ្រាប់រុក្ខជាតិ $(GM)$ ការពារស្រប ច្បាប់មិនឲ្យក្រុមហ៊ុនដទៃផលិតគ្រាប់រុក្ខជាតិ $(GM)$ នោះទេ។គ្រាប់រុក្ខជាតិមិនអាចតពូជបានទេ គឺត្រូវទិញពូជពីក្រុមហ៊ុនជារៀងរាល់ឆ្នាំ។

VII. ក. គណនាចំនួននុយក្លេអូទីតប្រភេទនីមួយៗរបស់ម៉ូលេគុល ADN

បម្រាប់

$$C = 35\%$$

$$C - A = 4400$$

តាមគោលការណ៍បំពេញបាស

$$A - T \; , C - G \quad \Rightarrow A = T \; , C = G$$

$$\%A + \%T + \%C + \%G = 100\%$$

$$2A + 2C = 100\%$$

$$A\% + \%C = 50\%$$

$$\Rightarrow \%A = 50\% - \%C = 50\% - 35\% = 15\%$$

តាម $C - A = 4400$ នុយក្លេអូទីត

$$\frac{35M}{100}-\frac{15M}{100}=4400$$

$$\frac{20M}{100}=4400 \Rightarrow M=\frac{440000}{20}=22000$$

$A=\frac{15\times 22000}{100}=3300$ នុយក្លេអូទីត

$C=\frac{35\times 22000}{100}=7700$ នុយក្លេអូទីត

ដូចនេះ: $A=T=3300$ នុយក្លេអូទីត
$C=G=7700$ នុយក្លេអូទីត

ខ. គណនាចំនួនជំហានរបស់ $ADN$

ដោយ1 ជំហាន $10=$គូបាស $20=$នុយក្លេអូទីត

តាមចំនួនជំហាន$=\frac{M}{20}=\frac{22000}{20}=1100$ ជំហាន

**ដូចនេះ:** $ADN$ មាន 110 ជំហាន

គរកចំនួននុយក្លអូទីតសេរី .

$ADN$ ស្វ័យតម្លើងទ្វេ 1លើកបាន$ADN$ កូន $2^1$

$ADN$ ស្វ័យតម្លើងទ្វេ 2លើកបានADN កូន $2^2$

$ADN$ ស្វ័យតម្លើងទ្វេ 3លើកបានADN កូន $2^3$

………………………………………………………..

$ADN$ ស្វ័យតម្លើងទ្វេ nលើកបាន$ADN$ កូន $2^n$

ដោយ $ADN$ ស្វ័យតម្លើងទ្វេ៤លើកបាន$ADN$ កូន$2^4$

ក្នុងនោះមាន $ADN$ មេ1 គេបាន$ADN$ កើតថ្មី $2^4-1=16-1=15$

$M'=M\times 15=22000\times 15=33\times 10^4$ នុយក្លេអូទីតសេរី

**ដូចនេះ:** នុយក្លេអូទីត $M'=33\times 10^4$

VIII. ក. គណនាចំនួននុយក្លអូទីតប្រភេទនីមួយៗរបស់សែន

បម្រាប់៖សមាមាត្រនុយក្លេអូទីត$U, A, C, G$ មានសមាមាត្រ$3,4,6,7$

ប្រវែង $0.408\mu m = 4080nm$

ដោយសែនជាច្រវ៉ាក់ពីស្របគ្នា ហើយនុយក្លេអូទីតនីមួយៗមានប្រវែង $0.34nm$

តាម $\ell = \frac{M}{2} \times 0.34$

$$M = \frac{2\ell}{0.34}$$
$$M = \frac{2 \times 408}{0.34}$$
$$M = 2400$$

នុយក្លេអូទីតសរុបនៅលើច្រវ៉ាក់ម្ខាង

$m = \frac{M}{2} = \frac{2400}{2} = 1200$ នុយក្លេអូទីត

តាមបម្រាប់៖

$$\frac{U}{3} = \frac{A}{4} = \frac{C}{6} = \frac{G}{7}$$
$$= \frac{U + A + C + G}{3 + 4 + 6 + 7} = \frac{m}{20} = \frac{1200}{20} = 60$$

គេបាន $\frac{U}{3} = 60 \Rightarrow U = 3 \times 60 = 180$ រីបូនុយក្លេអូទីត

គេបាន $\frac{A}{4} = 60 \Rightarrow A = 4 \times 60 = 240$ រីបូនុយក្លឹអូទីត

គេបាន $\frac{C}{6} = 60 \Rightarrow C = 6 \times 60 = 360$ រីបូនុយក្លេអុទីត

គេបាន $\frac{G}{7} = 60 \Rightarrow G = 7 \times 60 = 420$ រីបូនុយក្លេអុទីត

តាម $A = T = (A + U)_{ARNm} = (180 + 240) = 420$ នុយក្លេអូទីត

តាម $C = G = (C + G)_{ARNm} = (360 + 420) = 780$ នុយក្លេអូទីត

ដូចនេះ

| |
|---|
| $A = T = 420$ នុយក្លេអុទីត |
| $C = G = 780$ នុយក្លេអូទីត |

ខ. រកម៉ាសម៉ូលេគុលរបស់សែននីមួយៗ

បម្រាប់៖ ម៉ាសម៉ូលេគុលនីមួយៗជាមធ្យមរបស់សែនស្មើ 300 ខ្នាតកាបូន

តាមម៉ាសម៉ូលេគុល $A = T = A \times 300$

$= 420 \times 300$

$= 126000$ ខ្នាតកាបូន

តាមម៉ាសម៉ូលេគុល $C = G = C \times 300$

$= 780 \times 300$

$= 23400$ ខ្នាតកាបូន

<u>ដូចនេះ</u>

| |
|---|
| $A = T = 420$ នុយក្លេអូទីត |
| $C = G = 780$ នុយក្លេអុទីត |

គ. រកចំនួនរង្វេលជុំ

ដោយមួយរង្វេលជុំមាន 10 គូបាសស្មើនឹង 20 នុយក្លេអុទីត

តាមចំនួនរង្វេល $= \frac{M}{20} = \frac{2400}{20} = 120$ រង្វេល

**<u>ដូចនេះ</u>** ចំនួនរង្វេលជុំ $= 120$ រង្វេលជុំ